Co-funded by the
Erasmus+ Programme
of the European Union

ឈ្មោះគម្រោង**:** មជ្ឈមណ្ឌលអប់រំដើម្បីឧត្តមភាពក្នុងជំនាញឆ្មប

ចំណងជើងឯកសារ៖ មគ្គុទេសក៍ការអនុវត្តន៍ល្អបំផុត សម្រាប់ **SafeMa**
ឧត្តមភាពនៃការសិក្សា និងស្រាវជ្រាវក្នុងជំនាញឆ្មប

ចំណងជើងរង : **របាយការណ៍**
WP/ Task/ Deliverable: **WP1/Task 1.1/ D.1.1**

អ្នកនិពន្ធ: **UCN**

Co-funded by the
Erasmus+ Programme
of the European Union

ព័ត៌មានគម្រោង

អក្សរកាត់គម្រោង: **SafeMa**

ឈ្មោះគម្រោង: **មជ្ឈមណ្ឌលអប់រំជំនាញឆ្មប ដើម្បីឧត្តមភាព**

កិច្ចព្រមព្រៀងលេខ: **598946**

កម្មវិធីសហគមអ៊ឺរ៉ុប: **Erasmus +**

គេហទំព័រគម្រោង: **safema-project.eu**

រៀបចំដោយ:

ឈ្មោះ: **UCN**

ឯកភាពដោយតំណាងគម្រោង SafeMa

Disclaimer:

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union

តារាងមាតិកា

សារតាសង្ខេប 6

សេចក្តីណែនាំ 8

ជំពូកទី១– ពិនិត្យឡើងវិញនូវស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុតក្នុងការអប់រំ និងការស្រាវជ្រាវជំនាញឆ្មប 9

១.0 ការណែនាំអំពីជំពូក 9

១.១ ស្តង់ដាអន្តរជាតិ និងការអនុវត្តល្អបំផុតយោងទៅតាម ICM 9

១.១.១ គោលបំណងនៃឯកសារ ICM 9

១.១.២ ការអភិវឌ្ឍស្តង់ដា ICM 10

១.១.៣ បំណងប្រើប្រាស់ស្តង់ដាររបស់ ICM 10

១.១.៤ គោលការណ៏របស់ ICM 12

១.១.៥ ប្រធានបទសំខាន់របស់ICM 12

១.១.៦ បញ្ជីតាមស្តង់ដារពិភពលោករបស់ ICM 13

១.២ ស្តង់ដារអន្តរជាតិនិងការអនុវត្តល្អបំផុតយោងទៅតាមអង្គការសុខភាពពិភពលោក 17

១.២.១ គោលបំណងនៃឯកសាររបស់អង្គការសុខភាពពិភពលោក 18

១.២.២ ការអភិវឌ្ឍស្តង់ដារពិភពលោករបស់អង្គការសុខភាពពិភពលោក 18

១.២.៣ គោលបំណងប្រើប្រាស់ស្តង់ដារពិភពលោករបស់ WHO 18

១.២.៤ គោលការណ៍គាំទ្រស្តង់ដារពិភពលោករបស់ WHO 19

១.២.៥ ប្រធានបទសំខាន់ៗនៃស្តង់ដារពិភពលោករបស់ WHO 19

១.២.៦ ស្តង់ដារពិភពលោកដែលបានចុះបញ្ជី 20

១.៣ សេចក្តីសង្ខេបស្តង់ដាររបស់ ICM និងការអនុវត្តន៍ស្តង់ដារល្អបំផុត WHO 26

១.៣.១ ការអនុវត្តល្អបំផុត 27

១.៣.១.១ ការរៀនសូត្រនៅកន្លែងផ្សេងៗគ្នា 27

១.៣.១.២ ការចូលរួមរបស់និស្សិតក្នុងការកែលំអគុណភាព 28

១.៣.១.៣ ការអនុវត្តជាក់ស្តែងដែលផ្អែកលើការគិតត្រិះរិះពិចារណា 29

១.៣.១.៤ គ្រប់គ្រងធនធាននិងការអនុវត្តដើម្បីឆ្លើយតបតម្រូវការប្រជាជន 29

១.៣.១.៥ ការរៀនពីក្រមសីលធម៌ 30

១.៣.១.៦ ការអនុវត្តអន្តរវិជ្ជាជីវៈ 30

១.៣.២ ស្តង់ដារល្អបំផុត 30

១.៣.២.១ លក្ខខណ្ឌការចូលរៀន 31

១.៣.២.២ ការបញ្ចប់ការសិក្សា 31

១.៣.៣ វិធីសាស្ត្រល្អបំផុត 32

១.៣.៣.១ ទស្សនវិជ្ជានៃកម្មវិធីអប់រំឆ្មប 32

១.៣.៣.២ លក្ខខណ្ឌកំណត់គ្រូ និងគ្រូគ្លីនិក 33

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

១.៣.៣.៣ ការអភិវឌ្ឍកម្មវិធីសិក្សា 33
១.៣.៣.៤ ធនធាននិងឧបករណ៍សម្រាប់ការសិក្សា 34
១.៤ គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព 34
១.៤.១ ចំណុចស្នូលរបស់ SafeMa 35
ជំពូកទី ២ – សមត្ថភាពស្នូលសម្រាប់ជំនាញឆ្មបក្នុងគ្លីនិក 37
២.០ សេចក្តីផ្តើមនៃជំពូក 37
២.១ សមាសភាគក្នុងការអនុវត្តឆ្មប 38
២.១.១ សមត្ថភាពទី១៖ សមត្ថភាពសង្គម អេពីដេមីសាស្ត្រ និងការមើលថែមាតានិងទារក 38
២.១.២ សមត្ថភាពទី ២៖ សមត្ថភាពការថែទាំមុនពេលមានផ្ទៃពោះ និងផែនការគ្រួសារ 39
២.១.៣ សមត្ថភាពទី៣៖ សមត្ថភាពក្នុងការផ្តល់ការថែទាំអំឡុងពេលមានផ្ទៃពោះ 39
២.១.៤ សមត្ថភាពទី៤៖ សមត្ថភាពក្នុងការផ្តល់ការថែទាំកំឡុងពេលសម្រាលកូន 39
២.១.៥ សមត្ថភាពទី ៥៖ សមត្ថភាពការថែទាំដល់ស្ត្រីក្រោយពេលសម្រាល 40
២.១.៦ សមត្ថភាពទី ៦៖ សមត្ថភាពការថែទាំទារកក្រោយសម្រាល 40
២.១.៧ សមត្ថភាពទី៧៖ សមត្ថភាពការថែទាំទាក់ទងនឹងការរំលូតកូន 40
ជំពូកទី ៣ – អំពីសិទ្ធិមនុស្ស 41
៣.០ ការណែនាំអំពីជំពូក 41
៣.១ ទស្សនទានស្តីពីសិទ្ធិមនុស្សក្នុងបរិបទ SafeMa 41
៣.១.១ គោលដៅវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស 42
៣.១.២ ដំណើរការត្រូវផ្អែកលើការគោរពសិទ្ធិមនុស្ស 42
៣.១.៣ លទ្ធផលដែលផ្អែកលើការគោរពសិទ្ធិមនុស្ស 43
ជំពូកទី ៤ – ការស្រាវជ្រាវក្នុងជំនាញឆ្មប 43
៤.០ សេចក្តីផ្តើមជំពូក 43
៤.១ ការសិក្សាស្រាវជ្រាវក្នុងជំនាញឆ្មប 43
៤.២ ការអនុវត្តជាក់ស្តែង 45
ឯកសារពិគ្រោះ 47

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

សារគោសង្ខេប

គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីបង្កើតមគ្គុទ្ទេសដ៏ល្អប្រសើក្នុងការអប់រំស្រាវជ្រាវនិងអនុវត្ត នាញឆ្មប។ របាយការណ៍នេះគឺជាផ្នែកមួយនៃបរិបទដ៏ធំនៃគម្រោង SafeMa ហើយវានឹងក្លាយជាមូលដ្ឋាននៃការវិភាគគម្លាត របស់គម្រោង SafeMa ក្នុងដំណាក់កាលទី១ កិច្ចការទី២ ដែលមានគោលបំណងដើម្បីវាយតម្លៃស្តង់ដារដ៏ល្អប្រសើរដោយបានកំណត់នៅក្នុងរបាយការណ៍នេះ និងស្ថានភាពបច្ចុប្បន្ននៅក្នុងសាកលវិទ្យាល័យនិងប្រទេសជាដៃគូសហប្រតិបត្តិការ។

ឆ្លងតាមរយៈការពិនិត្យ និងសិក្សាស្តង់ដារអន្តរជាតិការអនុវត្តន៍ល្អបំផុតនិងវិធីសាស្ត្រនៅក្នុងការអប់រំ និងស្រាវជ្រាវលើជំនាញឆ្មប ការវិភាគប្រៀបធៀប ត្រូវបានធ្វើឡើង។ ផ្អែកលើការវិភាគប្រៀបធៀបនេះ ស្តង់ដារអន្តរជាតិនៃការអនុវត្តន៍ល្អបំផុត និងវិធីសាស្ត្រត្រូវបានគេកាត់ចេញ ហើយបានទុកតែចំណុចសំខាន់ៗ
ដូចខាងក្រោមដែលត្រូវបានចាត់ទុកជាធាតុដែលចាំបាច់ដើម្បីគោរពតាមស្តង់ដារអន្តរជាតិល្អបំផុត ក្នុងការអប់រំការស្រាវជ្រាវ និងអនុវត្តៈ

- ការរៀនក្នុងស្ថានភាពខុសគ្នា
- ការចូលរួមរបស់សិស្សក្នុងការកែលំអគុណភាព
- ការអប់រំដែលផ្តោតអនុវត្តជាក់ស្តែង និងការគិតពិចារណា
- ការគ្រប់គ្រងធនធាន និងការអនុវត្តដែលឆ្លើយតបតម្រូវការរបស់ប្រជាជន
- គោរពក្រមសីលធម៌
- ការអនុវត្តលើអន្តរវិជ្ជាជីវៈ
- លក្ខណ្ឌការចូលរៀន
- ការបញ្ចប់ការសិក្សា
- ទស្សនវិជ្ជានៃកម្មវិធីអប់រំឆ្មប
- លក្ខខណ្ឌការជ្រើសរើសសាស្ត្រាចារ្យ និងការធ្វើគ្លីនិក
- ការអភិវឌ្ឍកម្មវិធីសិក្សា
- ធនធាននិងឧបករណ៍សម្រាប់ការសិក្សា
- ការគោរពសិទ្ធិមនុស្ស
- ស្រាវជ្រាវនៅក្នុងជំនាញឆ្មប

របាយការណ៍នេះត្រូវបានចែកជា ៤ ជំពូក។ ជំពូកទី១ ការពិពណ៌នាអំពីស្តង់ដារអន្តរជាតិនៃសហព័ន្ធឆ្មបអន្តរជាតិ (ICM) ស្តង់ដារសាកលសម្រាប់ការអប់រំឆ្មប (ឆ្នាំ ២០១០) និងស្តង់ដាររបស់អង្គការសុខភាពពិភពលោកសម្រាប់ការអប់រំគិលានុបដ្ឋាក និងឆ្មប (ឆ្នាំ ២០០៩) ដោយយោងតាមឯកសារទាំងនេះ ដែលជាឯកសារគ្រឹះស្តីពីស្តង់ដារល្អបំផុតនិងការអនុវត្តល្អបំផុតអន្តរជាតិ។ ស្តង់ដារល្អបំផុតអន្តរជាតិទាំងនេះ ត្រូវបានសង្ខេបហើយនិងបានដាក់បញ្ចូលក្នុងគ្រោងសាងរបស់គម្រោង SafeMa។

ជំពូកទី២ គ្រោងស្តង់ដារល្អបំផុតក្នុងការអនុវត្តជំនាញឆ្មបជាមួយនិងសមត្ថភាពអនុវត្តមូលដ្ឋាន(ឆ្នាំ ២០១៣) របស់សហព័ន្ធឆ្មបអន្តរជាតិ (ICM) ជដែលមានគោលបំណងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការវិភាគក្នុងគម្រោង SafeMa ដំណាក់កាលទី១ និងកិច្ចការទី២។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ជំពូក៣ បង្ហាញពីការយកចិត្តទុកដាក់របស់គម្រោង SafeMa លើការគោរពសិទ្ធិមនុស្សដោយសង្កត់ធ្ងន់ទៅលើទស្សនៈនៃសិទ្ធិមនុស្សក្នុងការផ្តល់សេវាថែទាំ ប្រកបដោយគុណភាពនៅក្នុងប្រទេសជាដៃគូ។

ជំពូកទី៤ គូសបញ្ជាក់អំពីស្តង់ដារល្អបំផុតរបស់គម្រោង SafeMa សម្រាប់ការស្រាវជ្រាវក្នុងជំនាញឆ្មប ដោយសង្កត់ធ្ងន់ទៅលើវិធីសាស្ត្រការសិក្សាស្រាវជ្រាវ ដែលត្រូវបានប្រើប្រាស់ក្នុងការអប់រំនិងការអនុវត្តន៍ តាមរយៈគំនិតនៃការអនុវត្តផ្អែកលើភាពជាក់ស្តែង។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

សេចក្តីណែនាំ

គោលបំណងនៃរបាយការណ៍នេះគឺដើម្បីបង្កើតការណែនាំអំពីការអប់រំ ការស្រាវជ្រាវ និងអនុវត្តល្អបំផុតក្នុងជំនាញឆ្មប។

ឆ្លងតាមរយៈការពិនិត្យ និងសិក្សាស្តង់ដារអន្តរជាតិ ការអនុវត្តន៍គល្អបំផុតនិងវិធីសាស្ត្រនៅក្នុងការអប់រំ និងស្រាវជ្រាវលើជំនាញឆ្មប ការវិភាគប្រៀបធៀប ត្រូវបានធ្វើឡើង។ ផ្អែកលើការវិភាគប្រៀបធៀបនេះ ស្តង់ដារអន្តរជាតិនៃការអនុវត្តន៍គល្អបំផុត និងវិធីសាស្ត្រត្រូវបានគេកាត់ចេញ។

សេចក្តីណែនាំនេះ បានដាក់បញ្ចូលដោយបានពិចារណាលើស្ថានភាពជាក់ស្តែងថ្នាក់ជាតិ / តំបន់ / មូលដ្ឋានក្នុងប្រទេសដៃគូមានវៀតណាមនិងកម្ពុជា។ លើសពីនេះទៀត សេចក្តីណែនាំនេះ បានពិចារណាលើទស្សនៈស្តីពីការគោរពសិទ្ធិមនុស្ស និងការលើកកម្ពស់យេនឌ័រ ដើម្បីទទួលបានជោគជ័យក្នុងវិជ្ជាជីវៈ និងវប្បធម៌សង្គម ក្នុងការផ្តល់ការថែទាំប្រកបដោយគុណភាពនៅក្នុងប្រទេសដៃគូ។

របាយការណ៍នេះគឺជាផ្នែកមួយនៃបរិបទដ៏ធំនៃគម្រោង SafeMa ហើយវានឹងក្លាយជាមូល ដ្ឋាននៃការវិភាគគម្លាត របស់គម្រោង SafeMa ក្នុងដំណាក់កាលទី១ កិច្ចការទី២ ដែលមានគោលបំណងដើម្បីវាយតម្លៃស្តង់ដារដ៏ល្អប្រសើរ ដោយបានកំណត់នៅក្នុងរបាយការណ៍នេះ និងស្ថានភាពបច្ចុប្បន្ននៅក្នុងសាកលវិទ្យាល័យ និងប្រទេសជាដៃគូសហប្រតិបត្តិការ។

របាយការណ៍នេះត្រូវបានចែកជា ៤ ជំពូក។ ជំពូកទី១ ការពិពណ៌នាអំពីស្តង់ដារអន្តរជាតិនៃសហព័ន្ធឆ្មបអន្តរជាតិ (ICM) ស្តង់ដារសាកល សម្រាប់ការអប់រំឆ្មប (ឆ្នាំ២០១០) និងស្តង់ដាររបស់អង្គការសុខភាពពិភពលោកសម្រាប់ការអប់រំគិលានុបដ្ឋាក និងឆ្មប (ឆ្នាំ ២០០៩) ដោយយោងតាមឯកសារទាំងនេះ ដែលជាឯកសារគ្រឹះស្តីពីស្តង់ដារល្អបំផុតនិងការអនុវត្តល្អបំផុតអន្តរជាតិ។ ស្តង់ដារល្អបំផុតអន្តរជាតិទាំងនេះ ត្រូវបានសង្ខេបហើយ និងបានដាក់បញ្ចូលក្នុងគ្រោងសាងរបស់គម្រោង SafeMa។

ជំពូកទី២ គ្រោងស្តង់ដារល្អបំផុតក្នុងការអនុវត្តជំនាញឆ្មប ជាមួយនិងសមត្ថភាពអនុវត្តមូលដ្ឋាន(ឆ្នាំ ២០១៣) របស់សហព័ន្ធឆ្មបអន្តរជាតិ (ICM) ជដែលមានគោលបំណងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការវិភាគក្នុងគម្រោង SafeMa ដំណាក់កាលទី១ និងកិច្ចការទី២។ ជំពូក៣ បង្ហាញពីការយកចិត្តទុកដាក់លើការគោរពសិទ្ធិមនុស្ស។ ជំពូកទី៤ គូសបញ្ជាក់អំពីស្តង់ដារល្អបំផុតសម្រាប់ការស្រាវជ្រាវក្នុងជំនាញឆ្មប។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ជំពូកទី១ ពិនិត្យឡើងវិញនូវស្តង់ដារអន្តរជាតិ និង ការអនុវត្តល្អបំផុតក្នុងការអប់រំ និងការស្រាវជ្រាវជំនាញឆ្មប

១.០ ការណែនាំអំពីជំពូក

ខាងក្រោមនេះគឺជាការពិពណ៌នាអំពីស្តង់ដារសកលនៃការបណ្តុះបណ្តាលឆ្មប(ឆ្នាំ២០១៣)របស់សហពន្ធឆ្មបអន្តរជាតិ (ICM) និងស្តង់ដារពិភពលោករបស់អង្គការសុខភាពពិភពលោកសម្រាប់ការអប់រំគិលានុបដ្ឋាកនិងឆ្មប (២០០៩)។ ឯកសារទាំងនេះត្រូវបានរកឃើញតាមរយៈការសិក្សាពិនិត្យមើលដ៏ទូលំទូលាយ និងដើម្បីក្លាយជាឯកសារគ្រឹះក្នុងការពិពណ៌នាអំពីស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុត។ ដូច្នេះឯកសារទាំងអស់នេះនឹងបានជាគ្រឹះសម្រាប់ការណែនាំក្នុងគម្រោង SafeMa ដើម្បីផ្តល់នៅការអប់រំនិងការស្រាវជ្រាវល្អបំផុតលើជំនាញឆ្មប។

១.១ ស្តង់ដារអន្តរជាតិនិងការអនុវត្តល្អបំផុត តាមស្តង់ដារ **ICM**

ICM គឺជាសហព័ន្ធនៃសមាគមឆ្មបដែលតំណាងឱ្យប្រទេសនៅទូទាំងពិភពលោក។ ICM ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក និងទីភ្នាក់ងារទាំងអស់របស់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលក្នុងការគាំទ្រដល់មាតុភាពប្រកបដោយសុវត្ថិភាពនិងយុទ្ធសាស្ត្រថែទាំសុខភាពបឋមសម្រាប់ក្រុមគ្រួសារពិភពលោក។

១.១.១ គោលបំណងនៃឯកសារ **ICM**

ស្តង់ដារសាកលរបស់ ICM សម្រាប់ការអប់រំឆ្មបគឺជាសសរស្តម្ភដ៏សំខាន់ ដែល ICMចខិតខំប្រឹងប្រែងពង្រឹងទូទាំងពិភពលោក ដោយរៀបចំអ្នកជំនាញឆ្មបដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ដើម្បីផ្តល់នូវសេវាកម្មសុខភាពប្រកបដោយគុណភាពខ្ពស់ សេវាសុខភាបដែលផ្អែកលើភាពជាក់ស្តែងសម្រាប់ស្ត្រី ទារកទើបនឹងកើត។ ពាក្យ“លក្ខណ:សម្បត្តិគ្រប់គ្រាន់” សំដៅទៅលើឆ្មបដែលទទួលបានការអប់រំនិងបណ្តុះបណ្តាលជំនាញគ្រប់តាមលក្ខខណ្ឌរបស់ ICM ដែលបានពិពណ៌នានៅក្នុងឯកសារ (សមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបមូលដ្ឋាន) (៤)។

ស្តង់ដារអប់រំត្រូវបានបង្កើតឡើងជាបណ្តើរៗ ជាមួយនឹងការធ្វើបច្ចុប្បន្នភាពនៃសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបមូលដ្ឋាន ហើយសមត្ថភាពទាំងនេះត្រូវបានកំណត់ខ្លឹមសារស្នូលនៃកម្មវិធីអប់រំឆ្មប។

១.១.២ ការអភិវឌ្ឍស្តង់ដារ **ICM**

ស្តង់ដារអប់រំឆ្មបត្រូវបានបង្កើតឡើងសម្រាប់ការប្រើប្រាស់ទូទាំងពិភពលោកតាមរយៈការស្ទង់មតិ(Delphi)កំឡុងឆ្នាំ ២០០៩-២០១០ និងរំពឹងទុកអប្បបរមាសម្រាប់កម្មវិធីអប់រំឆ្មប ដោយសង្កត់ធ្ងន់ទៅលើគុណភាព ជាងសញ្ញាបត្រ។ គោលការណ៍ណែនាំត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងសំណួរដូចតទៅនេះ តើត្រូវការអ្វីខ្លះដើម្បីអនុវត្តស្តង់ដារនីមួយៗ (គោលការណ៍ណែនាំ)? និង តើនរណាអាចកំណត់ថាស្តង់ដារត្រូវបានឆ្លើយតបយ៉ាងដូចម្តេច?" (១) និងគោលការណ៍ណែនាំ ដើរតួនាទីជាការពន្យល់បន្ថែមនៃស្តង់ដារអប់រំឆ្មប ICM ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union

ICM បានសង្កត់ធ្ងន់ថាមានស្តង់ដារពិភពលោកសម្រាប់ការអប់រំឆ្មបដែលអាចប្រើប្រាស់ក្នុងបណ្តាប្រទេសនិងតំបន់ជាពិសេសប្រទេសដែលមិនទាន់មានស្តង់ដារនាពេលបច្ចុប្បន្ននេះ ការកំណត់គោលសម្រាប់ការអប់រំឆ្មបដោយផ្អែកលើបទដ្ឋានពិភពលោក។ ស្តង់ដារល្អបំផុតក៏ជួយកំណត់លទ្ធផលរំពឹងទុកសម្រាប់ការអនុវត្ត (សមត្ថភាព) និងវិសាលភាពនៃការអនុវត្តជំនាញឆ្មបសម្រាប់ប្រទេសឬតំបន់ដែលត្រូវការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងគ្រួសារបង្កើតកូន (១) ។ គោលបំណងរបស់ SafeMa ដើម្បីបង្កើតវគ្គបណ្តុះបណ្តាលជំនាញឆ្មបស្តីពី“ ការអនុវត្តន៍ឆ្មបកម្រិតខ្ពស់” (៥p:27) ស្តង់ដារពិភពលោក របស់ ICMនេះនឹងជួយកំណត់គោលដៅសម្រាប់ការអភិវឌ្ឍវគ្គសិក្សា។

១.១.៣ បំណងប្រើប្រាស់ស្តង់ដាររបស់ **ICM**

យោងទៅតាម ICM ការប្រើប្រាស់ស្តង់ដារទាំងនេះគឺដើម្បីជួយដល់អ្នកប្រើប្រាស់ចំនួនបីក្រុមៈ

- ប្រទេសដែលមិនទាន់មានការអប់រំឆ្មបមូលដ្ឋានប៉ុន្តែពួកគេចង់បង្កើតកម្មវិធីដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រទេសសម្រាប់បុគ្គលិកសុខាភិបាលដែលមានសមត្ថភាព។
- ប្រទេសដែលមានកម្មវិធីអប់រំឆ្មបមូលដ្ឋានហើយដែលបំណងចងកែលំអកម្មវិធីសិក្សាដើម្បីលើកកម្ពស់គុណភាព ឬធ្វើឱ្យកម្មវិធីកាន់តែមានស្តង់ដារ។
- ប្រទេសដែលមានស្តង់ដារស្រាប់ហើយសម្រាប់ការអប់រំឆ្មបដែលមានបំណងចង់ប្រៀបធៀបគុណភាពនៃកម្មវិធីរបស់ពួកគេទៅនឹងបទដ្ឋានអប្បបរមាទាំងនេះ (១)

ទាំងពីរប្រទេសកម្ពុជានិងប្រទេសវៀតណាមមានកម្មវិធីសិក្សាប្រកបដោយស្តង់ដារសម្រាប់ការអប់រំឆ្មបនិងមានខ្លឹមសារផ្សេងៗគ្នាដែលអាចកំណត់យកសម្រាប់អ្នកប្រើប្រាស់ទាំងបីក្រុមនេះ។ ទាំងពីរប្រទេសកម្ពុជានិងប្រទេសវៀតណាមមានដំណើរវិវឌ្ឍគួរឱ្យកត់សម្គាល់ចាប់តាំងពីនសតវត្សឆ្នាំ ១៩៩០ មានអត្រា ៨៩% និង ៩៤% ដែលចូលរួមដោយអ្នកថែទាំកំណើតដែលមានជំនាញខ្ពស់។ ទោះបីជានៅក្នុងប្រទេសទាំងពីរភាគច្រើននៃការសម្រាលកូននៅតាមតំបន់ជនបទនៅតែត្រូវបានធ្វើឡើងនៅផ្ទះដោយអ្នកសំរាលកូនតាមប្រពៃណីដែលមិនបានទទួលការបណ្តុះបណ្តាល។ ប្រទេសកម្ពុជាវាជាអាទិភាពចំបងដើម្បីបន្តពង្រឹងសមត្ថភាពរបស់ឆ្មបដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិសុខភាពផ្លូវភេទនិងសុខភាពបន្តពូជនៅកម្ពុជា ២០១៧-២០២១ ។ ប្រទេសវៀតណាម មានអត្រា ៥% មណ្ឌលសុខភាពប្រចាំឃុំមិនមានឆ្មបដែលទទួលបានការបណ្តុះបណ្តាលទេ នេះបើយោងតាមរបាយការណ៍នាយដ្ឋានសុខភាពមាតានិងទារក (ឆ្នាំ ២០១០) (៥ ទំព័រ ២៣-២៤)

ដូច្នេះ ការប្រើប្រាស់ឯកសារនេះ មានការពាក់ព័ន្ធនឹងគោលបំណងការណែនាំហើយបានសង្កត់ធ្ងន់បន្ថែមទៀតលើភាពពាក់ព័ន្ធសម្រាប់ការវិភាគគម្លាតនៅក្នុង គម្រោង SafeMa ក្នុង WP1 និងTask ទី2 ។

ICM បានសង្កត់ធ្ងន់ថានឹងមានការយល់គ្នារវាងប្រទេសមួយចំនួនដែលមានបំណងចាប់ផ្តើមនិងធ្វើឱ្យប្រសើរឡើងសម្រាប់ការបណ្តុះបណ្តាលឆ្មប ឱ្យមានជំនាញ

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

សមត្ថភាពការអនុវត្តឆ្មបមូលដ្ឋាន របស់ICM (ឆ្នាំ ២០១០) ហើយប្រហែលជាមិនអាចទទួលបានគ្រប់ស្តង់ដារអប្បបរមាដំបូងឡើយ ជាពិសេសនៅក្នុងតំបន់ដែលគ្រូបង្រៀនឆ្មបដែលមានសមត្ថភាពមិនទាន់គ្រប់គ្រាន់។ គេរំពឹងទុកថាប្រទេសដៃគូទាំងនេះ នឹងធ្វើការសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាល ស្ថាប័នអប់រំ ម្ចាស់ជំនួយនិងអ្នកពិគ្រោះយោបល់ផ្នែកឆ្មបដើម្បីបង្កើតផែនការសម្រាប់ការសំរេចអោយបានតាមស្តង់ដារការអប់រំ (១) ។ វាគឺជាគោលបំណងរបស់គម្រោង SafeMa ដើម្បីគាំទ្រដល់កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាននិងថ្នាក់ជាតិ និងសេវាផ្តល់សុខភាព សមាគមឆ្មបនិងអ្នកពាក់ព័ន្ធដទៃទៀត (៥ ទំព័រ ២៧)

១.១.៤ គោលការណ៍របស់ **ICM**

ICM បានដាក់បញ្ចូលគុណតម្លៃនិងគោលការណ៍គ្រឹះដែលបានកំណត់បទដ្ឋានស្តង់ដារ (១ P ២) ដែលមានដូចខាងក្រោម៖

- ជំរុញការជឿទុកចិត្តលើដំណើរការអប់រំឆ្មបតាមរយៈការអភិវឌ្ឍជាសកលនៃស្តង់ដារការអប់រំឆ្មបដោយឆ្មបនិងក្រុមជំនាញដែលបានជ្រើសរើស។
- ជំរុញនិងគាំទ្រដល់ការកែលំអគុណភាពជាបន្តនៅក្នុងកម្មវិធីបណ្តុះបណ្តាលនិងលទ្ធផលនៃការបណ្តុះបណ្តាល
- រក្សាភាពស្មោះត្រង់តាមរយៈដំណើរការអប់រំប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌និងស្មោះត្រង់
- ជំរុញបរិយាកាសអប់រំដែលគាំទ្រដល់និស្សិតដែលបានបញ្ចប់ការសិក្សានិងសាស្ត្រាចារ្យក្នុងការបន្តការរៀនសូត្រពេញមួយជីវិត
- លើកកម្ពស់ស្វ័យភាពនៃវិជ្ជាជីវៈឆ្មប និងកម្មវិធីសិក្សារបស់ឆ្មប។
- បង្កើតគោលការណ៍គ្រឹះរួមបញ្ចូលទាំងកិច្ចព្រមព្រៀងនានា
- កំរិតអប្បបរមាចំនួននិស្សិតចូលរៀន និងបញ្ចប់ការសិក្សា
- កំរិតរយៈពេលអប្បបរមា៣ឆ្នាំ សម្រាប់កម្មវិធីអប់រំឆ្មប
- កំរិតរយៈពេលអប្បបរមា១៨ខែ សម្រាប់កម្មវិធីអប់រំក្រោយឧត្តម
- ស្តង់ដារមានភាពស៊ីគ្នាជាមួយឯកសារគោល ICM និងរបាយការណ៍ជំហរទាក់ទងនឹងការរៀបចំគ្រូបង្រៀនឆ្មប និងឆ្មបដែលមានសមត្ថភាពពេញលេញ។
- កម្មវិធីឆ្មបនឹងចូលរួមក្នុងការវាយតម្លៃខ្លួនឯងលើបុគ្គលិក នីតិវិធី និងសេវាកម្មដើម្បីរក្សាគុណភាពនិងកម្មវិធីដែលសមនឹងគោលបំណងនៅក្នុងប្រទេសដែលផ្តល់ឱ្យ។

១.១.៥ ប្រធានបទសំខាន់របស់**ICM**

ឯកសារនេះចែកចេញជា ៦ ប្រធានបទសំខាន់នៃស្តង់ដារពិភពលោកសម្រាប់ការអប់រំឆ្មប (១) មានដូចខាងក្រោម៖

១. ការរៀបចំ និងការគ្រប់គ្រង
២. សាស្ត្រាចារ្យ ឆ្មប

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៣. និស្សិត
៤. កម្មវិធីសិក្សា
៥. ធនធាន ទីកន្លែង និងសេវាកម្ម
៦. យុទ្ធសាស្ត្រការវាយតម្លៃ

១.១.៦ បញ្ជីតាមស្តង់ដារពិភពលោករបស់ **ICM**

ខាងក្រោមនេះស្តង់ដារពិភពលោក ICM សម្រាប់ការអប់រំឆ្មបនឹងត្រូវបានចុះបញ្ជី

ស្តង់ដារទី១ ការរៀបចំនិងការគ្រប់គ្រងបទដ្ឋាន

១.១ គ្រឹះស្ថានអប់រំ / ទីភ្នាក់ងារ / អង្គភាពជំនាញរបស់រដ្ឋាភិបាលគាំទ្រដល់ទស្សនវិស័យ គោលបំណង និងកម្មវត្ថុនៃកម្មវិធីអប់រំឆ្មប។

១.២ គ្រឹះស្ថានអប់រំត្រូវធានាដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសាធារណៈ /គោលនយោបាយសម្រាប់កម្មវិធីអប់រំឆ្មប ដើម្បីរៀបចំអោយឆ្មបដែលមានសមត្ថភាព។

១.៣ គ្រឹះស្ថានអប់រំ និងកម្មវិធីអប់រំឆ្មប ត្រូវផែនមានថវិកា និងថវិកាសម្រាប់ដំណើរដែលស្របទៅនឹងតម្រូវរបស់ការកម្មវិធី។

១.៤ សាស្ត្រាចារ្យឆ្មប ត្រូវគ្រប់គ្រងដោយខ្លួនឯងនិងទទួលខុសត្រូវក្នុងការអភិវឌ្ឍនិងដឹកនាំគោលនយោបាយ និងកម្មវិធីសិក្សា។

១.៥ ប្រធានកម្មវិធីឆ្មប គឺជាគ្រូបង្រៀនឆ្មបដែលមានសមត្ថភាព មានបទពិសោធន៍ក្នុងការគ្រប់គ្រង និង រដ្ឋបាល។

១.៦ កម្មវិធីឆ្មប ត្រូវគិតគូរពីគោលនយោបាយនិងស្តង់ដារជាតិនិងអន្តរជាតិដើម្បីឆ្លើយតបនឹងតម្រូវការកម្លាំងពលកម្មមាតុភាព។

ស្តង់ដារទី២ អំពីសាស្ត្រាចារ្យ

ស្តង់ដារទី២.១ សាស្ត្រាចារ្យ ត្រូវមានសាស្ត្រចារ្យជំនាញឆ្មបច្រើនលើសលុប ទាំងគ្រូបង្រៀនទ្រឹះស្តី និងអនុវត្ត ដែលជាអ្នកជំនាញមកពីស្ថាប័នផ្សេងៗ តាមតម្រូវការចាំបាច់

ស្តង់ដារទី២.២.១ គ្រូបង្រៀនឆ្មបត្រូវមានការរៀបចំផែនការបង្រៀនអោយបានត្រឹមត្រូវ

ស្តង់ដារទី២.២.២ គ្រូបង្រៀនឆ្មបត្រូវមានសមត្ថភាពក្នុងការអនុវត្ត យ៉ាងតិច២ឆ្នាំ

ស្តង់ដារទី២.២.៣ គ្រូបង្រៀនឆ្មបត្រូវចុះបញ្ជីនៅគណៈឆ្មប ឬមានលិខិតគតិយុត្តិណាមួយដែលទទួលស្គាល់ដោយស្ថាប័នពាក់ពន្ធ។

ស្តង់ដារទី២.២.៤ គ្រូបង្រៀនឆ្មបត្រូវបានតែងតាំងជាគ្រូបង្រៀន ឬមានលិខិតចាត់តាំងដើម្បីចូលបំពេញការងារបង្រៀន។

ស្តង់ដារទី២.២.៥ គ្រូបង្រៀនឆ្មបត្រូវបណ្តុះបណ្តាលបន្ថែមសមត្ថភាព ទាំងទ្រឹះស្តីនិងអនុវត្ត

ស្តង់ដារទី២.៣.១ គ្រូគ្លីនិកឆ្មប និងគ្រូដឹកនាំ ត្រូវមានសមត្ថភាពស្របតាមលក្ខខណ្ឌរបស់ ICM

ស្តង់ដារទី២.៣.២ គ្រូគ្លីនិក និងគ្រូដឹកនាំត្រូវមានគ្រូជំនាញឆ្មបលើសលុប ហើយជាទូទៅត្រូវអនុវត្ត

រយៈពេល ២ឆ្នាំ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ស្តង់ដារទី២.៣.៣ គ្រូគ្លីនិកឆ្មប និងគ្រូដឹកនាំ ត្រូវរក្សាសមត្ថភាពក្នុងការបង្រៀន និងដឹកនាំអនុវត្ត

ស្តង់ដារទី២.៣.៣ គ្រូគ្លីនិកឆ្មប និងគ្រូដឹកនាំត្រូវចុះបញ្ជីនៅគណៈឆ្មប ឬមានលិខិតគតិយុត្តិណាមួយដែលទទួលស្គាល់ដោយស្ថាប័នពាក់ពន្ធ។

ស្តង់ដារទី២.៣.៤ គ្រូគ្លីនិកឆ្មប និងគ្រូដឹកនាំ ត្រូវបានតែងតាំងជាគ្រូបង្រៀន ឬមានលិខិតចាត់តាំងដើម្បីចូលបំពេញការងារបង្រៀន។

ស្តង់ដារទី២.៤ គ្រូបង្រៀនក្នុងកម្មវិធីងណ្តុះបណ្តាលឆ្មបត្រូវមានខ្លឹមសារសមស្របជាមួយកម្មវិធី។

ស្តង់ដារទី២.៥ គ្រូបង្រៀនត្រូវផ្តល់ការបណ្តុះបណ្តាល ការគាំទ្រ និងការណែនាំដល់និស្សិតដែលខ្លួនឯងដឹកនាំអនុវត្ត និងបង្រៀន។

ស្តង់ដារទី២.៦ គ្រូបង្រៀន និងគ្រូគ្លីនិក ត្រូវធ្វើការជាមួយគ្នាដើម្បីគាំទ្រនិងការណែនាំដល់និស្សិតដែលខ្លួនឯងដឹកនាំអនុវត្ត និងបង្រៀន។

ស្តង់ដារទី២.៧ សមាមាត្រនិស្សិត ទៅនឹងគ្រូ និងគ្រូគ្លីនិកនៅក្នុងថ្នាក់រៀននិងកន្លែងអនុវត្តជាក់ ស្តែងត្រូវបានកំណត់ដោយកម្មវិធី និងបទប្បញ្ញត្តិរបស់អាជ្ញាធរ។

ស្តង់ដារទី២.៨ ប្រសិទ្ធភាពរបស់គ្រូឆ្មបត្រូវបានវាយតម្លៃជាប្រចាំបន្ទាប់ពីដំណើរការដែលបានបង្កើតឡើង។

ស្តង់ដារទី៣ អំពីនិស្សិត

ស្តង់ដារទី៣.១ កម្មវិធីសិក្សារបស់ឆ្មបត្រូវកំណត់អោយបានច្បាស់លាស់ស្តីពីគោលការណ៍ចុះឈ្មោះចូលរៀន ដែលងាយស្រួលដល់បេក្ខភាព។

ស្តង់ដារទី៣.១.១ គោលការណ៍ស្តីពីការចុះឈ្មោះចូលរៀន ត្រូវបញ្ចូលលក្ខខណ្ឌអប្បរិមាពិន្ទុពីមធ្យមសិក្សា (បាក់ឌុប)។

ស្តង់ដារទី៣.១.២ ការចុះឈ្មោះចូលរៀនត្រូវតែពិនិត្យលើភាពត្រឹមត្រូវនៃដំណើរការជ្រើសរើស

ស្តង់ដារទី៣.១.៣ ការចុះឈ្មោះចូលរៀន គឺរួមបញ្ចូលទាំងដំណើរជ្រើសរើស និងលក្ខខណ្ឌទទួលពាក្យចូលរៀន។

ស្តង់ដារទី៣.១.៤ គោលការណ៍នៃការចូលរៀនរួមមានយន្តការសម្រាប់ពិចារណាពីការសិក្សា។

ស្តង់ដារទី៣.២ បេក្ខជនឆ្មបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានទទួលស្គាល់ដោយគ្មានការរើសអើង (ឧ. ភេទ អាយុ ជាតិសាសនាជាដើម)។

ស្តង់ដារទី៣.៣ បេក្ខជនឆ្មបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានទទួលយកតាមគោលការណ៍ថែទាំសុខភាពថ្នាក់ជាតិនិងផែនការកម្លាំងពលកម្មមាតុភាព។

ស្តង់ដារទី៣.៤ កម្មវិធីសិក្សាត្រូវតែចែងអោយបានច្បាស់ស្តីពីគោលការណ៍និស្សិត

ស្តង់ដារទី៣.៤.១ គោលការណ៍ស្តីពីនិស្សិតត្រូវចែងពីការរំពឹងទុករបស់និស្សិតទាំងក្នុងថ្នាក់រៀន និងការអនុវត្ត។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ស្តង់ដារទី៣.៤.២ គោលការណ៍ស្តីពីនិស្សិតត្រូវរួមបញ្ចូលពីរបាយការណ៍ស្តីពីសិទ្ធិរបស់និស្សិត និងការទទួលខុសត្រូវ និងដំណើរការដែលបានបង្កើតឡើងសម្រាប់ដោះស្រាយបណ្តឹងរបស់សិស្ស។

ស្តង់ដារទី៣.៤.៣ គោលការណ៍ស្តីពីនិស្សិតរួមមានយន្តការសម្រាប់និស្សិតក្នុងការផ្តល់យោបល់និងវាយតម្លៃជាបន្តនៃកម្មវិធីសិក្សាឆ្មបនិងគ្រូបង្រៀន។

ស្តង់ដារទី៣.៤.៤ គោលការណ៍ស្តីពីនិស្សិតត្រូវរួមបញ្ចូលពីលក្ខខណ្ឌនៃការបញ្ចប់ការសិក្សាសម្រាប់កម្មវិធី ឆ្មបនេះ។

ស្តង់ដារទី៣.៥ យន្តការដែលមានស្រាបសម្រាប់ការចូលសកម្មភាពនានារបស់និស្សិតក្នុងគណៈកម្មការគ្រប់គ្រងកម្មវិធី។

ស្តង់ដារទី៣.៦ និស្សិតដែលមានបទពិសោធន៍ខ្ពស់ក្នុងការអនុវត្តគ្រប់គ្រាន់ក្នុងភាពខុសប្លែកពីគ្នាត្រូវបានរាប់បញ្ចូលក្នុង សមត្ថភាពអនុវត្តមូលដ្ឋានរបស់ ICM។

ស្តង់ដារទី៣.៧ ផ្តល់ការមើលថែនិស្សិតជាចម្បងក្រោមការត្រួតពិនិត្យរបស់គ្រូ ឬគ្រូដឹកនាំអនុវត្ត។

ស្តង់ដារទី៤ កម្មវិធីសិក្សា

ស្តង់ដារទី៤.១ ទស្សនទានរបស់កម្មវិធីបណ្តុះបណ្តាលឆ្មប ត្រូវស្របតាមទស្សនទាន និងគំរូនៃការថែទាំរបស់ ICM។

ស្តង់ដារទី៤.២ គោលបំណងរបស់កម្មវិធីបណ្តុះបណ្តាលឆ្មប ត្រូវផលិតឆ្មបមានសមត្ថភាព។

ស្តង់ដារទី៤.២.១ ឆ្មបដែលមានសមត្ថភាពនឹងត្រូវបានទទួលយកតាមលក្ខខណ្ឌសមត្ថភាពដែលមានក្នុង ICM សម្រាប់ ការអនុវត្តឆ្មបមូលដ្ឋាន

ស្តង់ដារទី៤.២.២ ឆ្មបដែលមានសមត្ថភាពត្រូវបំពេញគ្រប់លក្ខខណ្ឌរបស់ ICM ស្តីពីបទបញ្ញត្តិនៃការចុះឈ្មោះចូលក្នុងគណៈឆ្មប។

ស្តង់ដារទី៤.២.៣ ឆ្មបដែលមានសមត្ថភាពមានសិទ្ធិដាក់ពាក្យសុំបន្តការអប់រំកម្រិតខ្ពស់។

ស្តង់ដារទី៤.២.៤ ឆ្មបដែលមានសមត្ថភាពគឺជាអ្នកអនុវត្តស្វ័យភាពនិងមានចំណេះដឹងដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌អន្តរជាតិ ស្តង់ដារវិជ្ជាជីវៈ និងបង្កើតវិសាលភាពនៃការអនុវត្តក្នុងដែនសមត្ថកិច្ចដែលមានការទទួលស្គាល់ជាផ្លូវការ។

ស្តង់ដារទី៤.៣ លំដាប់លំដោយនិងខ្លឹមសារនៃកម្មវិធីសិក្សាឆ្មបជួយឱ្យសិស្សទទួលបាននូវសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបស្របតាមឯកសារស្នូលរបស់ICM។

ស្តង់ដារទី៤.៤ កម្មវិធីសិក្សាឆ្មប រួមមានទាំងទ្រឹស្តី និងអនុវត្តន៍ ចំណែកទ្រឹស្តីមានអប្បបរមា ៤០ ភាគរយ និងការអនុវត្តអប្បបរមា ៥០ ភាគរយ។

ស្តង់ដារទី៤.៥ កម្មវិធីសិក្សាឆ្មប ប្រើវិធីសាស្រ្តផ្អែកលើភ័ស្តុតាងក្នុងការបង្រៀននិងការរៀនសូត្រដែលជម្រុញការសិក្សាមនុស្សពេញវ័យនិងការអប់រំផ្អែកលើជំនាញ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ស្តង់ដារទី៤.៦ កម្មវិធីសិក្សាឆ្មបផ្តល់ឱកាសសម្រាប់មាតិកាពហុមុខវិជ្ជានិងបទពិសោធន៍រៀនសូត្រដែលបំពេញបន្ថែមលើមាតិកាឆ្មប។

ស្តង់ដារទី៥ ធនធាន សម្ភារៈរូបវន្ត និងសេវាកម្ម

ស្តង់ដារទី៥.១ គោលការណ៍របស់កម្មវិធីសិក្សាឆ្មបស្តីពីការអនុវត្តបានសរសេរជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ពីសុវត្ថិភាពនិស្សិត និងគ្រូក្នុងបរិយាកាសល្អក្នុងការបង្រៀននិងរៀន។

ស្តង់ដារទី៥.២ កម្មវិធីសិក្សាឆ្មបត្រូវមានធនធានបង្រៀននិងរៀនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការកម្មវិធី។

ស្តង់ដារទី៥.៣ កម្មវិធីសិក្សាឆ្មបត្រូវមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីទ្រទ្រង់ទាំងថ្នាក់រៀន / ទ្រឹស្តីនិងការសិក្សាជាក់ស្តែង។

ស្តង់ដារទី៥.៤ កម្មវិធីសិក្សាឆ្មបត្រូវទទួលបានបទពិសោធន៍អនុវត្តជាក់ស្តែងដើម្បីបំពេញតំរូវការសិក្សារបស់និស្សិតម្នាក់ៗ។

ស្តង់ដារទី៥.៥. លក្ខណៈវិនិច្ឆ័យជ្រើសរើសសម្រាប់ការសិក្សាជាក់ស្តែង ត្រូវបានចែងទុកនិងអនុវត្តយ៉ាងច្បាស់។

ស្តង់ដារទី៦ អំពីយុទ្ធសាស្រ្តវាយតម្លៃ

ស្តង់ដារទី៦.១. គ្រូបង្រៀនឆ្មបត្រូវប្រើវិធីសាស្រ្តវាយតម្លៃនិងបូកសរុបអោយបានត្រឹមត្រូវដែលអាចទុកចិត្តបានដើម្បីវាស់វែងលទ្ធផលនិស្សិត និងវឌ្ឍនភាពក្នុងការរៀនទាក់ទងទៅ ក. ចំណេះដឹង ខ. ឥរិយាបថ គ. ជំនាញអនុវត្ត ឃ. ការត្រិះរិះពិចារណានិងធ្វើការសំរេចចិត្ត ង. ទំនាក់ទំនងរវាងបុគ្គល និងជំនាញទំនាក់ទំនង។

ស្តង់ដារទី៦.២ មធ្យោបាយនិងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើលទ្ធផលនៃដំណើរការ និងការរីកចម្រើនរបស់និស្សិតរួមទាំងការកំណត់អត្តសញ្ញាណនៃការលំបាកក្នុងការសិក្សាត្រូវបានសរសេរនិងចែករំលែកជាមួយសិស្ស។

ស្តង់ដារទី៦.៣ គ្រូបង្រៀនឆ្មបត្រូវធ្វើការពិនិត្យឡើងវិញជាទៀងទាត់នូវកម្មវិធីសិក្សាដែលជាផ្នែកមួយនៃការកែលំអគុណភាពរួមទាំងការបញ្ចូលទាំងធាតុចូលពីនិស្សិត និស្សិតបញ្ចប់ការសិក្សាឆ្មបដែលកំពុងបម្រើការងារ និងអ្នកពាក់ព័ន្ធដទៃទៀត។

ស្តង់ដារទី៦.៤ គ្រូបង្រៀនឆ្មបត្រូវធ្វើការត្រួតពិនិត្យបន្តនូវទីតាំងសិក្សាជាក់ស្តែងនិងភាពសមស្របរបស់ពួកគេសម្រាប់ការសិក្សាបទពិសោធន៍ទាក់ទងនឹងលទ្ធផលរំពឹងទុក។

ស្តង់ដារទី៦.៥ ការត្រួតពិនិត្យរយៈវេលាពីខាងក្រៅពីប្រសិទ្ធភាពនៃកម្មវិធី។

១.២ ស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុតយោងទៅតាមអង្គការសុខភាពពិភពលោក

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

អង្គការសុខភាពពិភពលោក (WHO) គឺជាអង្គការពិភពលោកមួយដែលមានតួនាទីចម្បងក្នុងការដឹកនាំនិងសម្របសម្រួលផ្នែកសុខភាពអន្តរជាតិនៅក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ។ អង្គការសុខភាពពិភពលោកធ្វើការជាមួយរដ្ឋចំនួន ១៩៤ ទូទាំងតំបន់ចំនួន ៦ ដោយមានការប្តេជ្ញាចិត្តរួមគ្នាដើម្បីទទួលបានសុខភាពសម្រាប់មនុស្សគ្រប់រូបគ្រប់ទីកន្លែង។

១.២.១ គោលបំណងនៃឯកសាររបស់អង្គការសុខភាពពិភពលោក

ស្តង់ដារពិភពលោករបស់អង្គការសុខភាពពិភពលោកសម្រាប់ការអប់រំគិលានុបដ្ឋាកនិងឆ្មប (ឆ្នាំ ២០០៩) គឺជាសសរស្តម្ភសំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងរបស់អង្គការសុខភាពពិភពលោកក្នុងការពង្រឹងឆ្មបនិងគិលានុបដ្ឋាកនៅទូទាំងពិភពលោក ព្រោះវិជ្ជាជីវៈទាំងនេះគឺជាកម្លាំងដ៏សំខាន់ក្នុងការធ្វើអោយប្រសើរនៅសេវាថែទាំសុខភាពពិភពលោក (៣)។ ដូច្នេះស្តង់ដារពិភពលោកបានសង្កត់ធ្ងន់លើជំនាញទាំងពីរឆ្មបនិងគិលានុបដ្ឋាក ការណែនាំនេះនឹងផ្តោតលើឆ្មបស្របតាមការផ្តោតរបស់គម្រោង SafeMa ។

១.២.២. ការអភិវឌ្ឍស្តង់ដារពិភពលោករបស់អង្គការសុខភាពពិភពលោក

ការអភិវឌ្ឍស្តង់ដារពិភពលោករបស់អង្គការសុខភាពពិភពលោកសម្រាប់ការអប់រំរបស់គិលានុបដ្ឋាកនិងឆ្មបបានចំណាយពេលជាង ៣ ឆ្នាំ។ កិច្ចប្រជុំរបស់ភាគីពាក់ព័ន្ធស្តីពីការចូលរួមវិភាគទានរបស់គិលានុបដ្ឋាកនិងឆ្មបដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ដែលអង្គការសុខភាពពិភពលោកបានកោះប្រជុំកាលពីខែឧសភាឆ្នាំ ២០០៥ បានបង្កើតទិសដៅយុទ្ធសាស្ត្រជាក់លាក់សម្រាប់ការអភិវឌ្ឍស្តង់ដារ។ ក្រោយមកនៅចុងឆ្នាំ ២០០៥ ក្រុមរៀបចំផែនការដឹកនាំដោយអង្គការសុខភាពពិភពលោកនិងស៊ីហ្គាម៉ាធីតាអន្តរជាតិ អង្ការសង្គមស៊ីវិលគិលានុបដ្ឋាកអន្តរជាតិកិត្តិយសត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យផែនការដំបូងនិងការអនុវត្តស្តង់ដារ។ នៅខែមីនាឆ្នាំ ២០០៦ អ្នកអប់រំផ្នែកថែទាំបានធ្វើការពិនិត្យឡើងវិញលើបទដ្ឋានដែលមានស្រាប់និងចងក្រងឯកសារសំយោគ។ ការជ្រើសរើសយ៉ាងហ្មត់ចត់នៃស្តង់ដារអប់រំដែលមានស្រាប់ពីជុំវិញពិភពលោកត្រូវបានចងក្រងជាឯកសារប្រវត្តិវិភាគសំយោគនិងប្រើប្រាស់ក្នុងការកសាងការមូលមតិគ្នា។ ពេញមួយឆ្នាំ ២០០៦ និង ២០០៧ វិធីសាស្ត្របន្ថែមត្រូវបានរៀបចំនិងអនុវត្ត - រួមមានការត្រួតពិនិត្យនិងវិភាគតាមរយៈអ្នកជំនាញនិងមតិយោបល់ត្រឡប់ពីសាធារណៈជននិងការសំយោគទិន្នន័យ។ ការឆ្លើយតបជាសាធារណៈជាង ១០០ ត្រូវបានវិភាគនិងសំយោគដោយក្រុមអ្នកជំនាញ។ ស្តង់ដាររៀបចំឡើងវិញនិងបញ្ជូនទៅទីប្រឹក្សាគិលានុបដ្ឋាកក្នុងតំបន់ដើម្បីពិនិត្យចុងក្រោយ ហើយឯកសារស្តង់ដារពិភពលោកត្រូវបានដាក់អោយដំណើរការ ។

១.២.៣ គោលបំណងប្រើប្រាស់ស្តង់ដារពិភពលោករបស់ **WHO**

អង្គការសុខភាពពិភពលោកកំណត់ពីការប្រើប្រាស់សក្តានុពលនៃស្តង់ដារពិភពលោកក្នុងសកម្មភាពផ្សេងៗដូចជា៖

១. បង្កើតវិធីសាស្ត្រសកលក្នុងការផ្តល់កម្មវិធីអប់រំផ្នែកលើភស្តុតាង

២. ការអនុវត្តសមត្ថភាពដែលបានបង្កើតឡើងដូចជាការបោះពុម្ពផ្សាយរបស់ ICM ដើម្បីផ្តល់ជាណែនាំសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៣. ជំរុញការបង្កើតសាលាឆ្មបនិងកម្មវិធីដែលឆ្លើយតបទៅនឹងតម្រូវការនិងការរំពឹងទុករបស់ជាតិថ្នាក់តំបន់និងសង្គម។

៤. ការបង្កើតគោលការណ៍សម្រាប់ការកែលម្អគុណភាព និងបន្តការអប់រំផ្នែកគិលានុបដ្ឋាកនិងឆ្មប។

អង្គការសុខភាពពិភពលោកបញ្ជាក់បន្ថែមពីស្តង់ដារពិភពលោកទាំងនេះអាចដើរតួជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍស្តង់ដារពិភពលោកសម្រាប់ការអប់រំគិលានុបដ្ឋាក ឬឆ្មបកម្រិតខ្ពស់។ ដូច្នេះរបាយការណ៍នេះត្រូវបានចាត់ទុកថាពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍនៃការពិនិត្យឡើងវិញនៅស្តង់ដារអន្តរជាតិនិងការអនុវត្តល្អបំផុតនៅក្នុងការអប់រំនិងការស្រាវជ្រាវឆ្មប។

១.២.៤ គោលការណ៍គាំទ្រស្តង់ដារពិភពលោករបស់ **WHO**

យោងតាមអង្គការសុខភាពពិភពលោក មានកត្តាសំខាន់ជាច្រើនដែលពាក់ពន្ធនឹងការអនុវត្តនិងលទ្ធផលនៃស្តង់ដារពិភពលោក។ គោលការណ៍ ៣ ខាងក្រោមនេះគាំទ្រស្តង់ដារទាំងអស់៖

១. សមត្ថភាពដែលបានបង្កើតឡើងដើម្បីផ្តល់នូវមូលដ្ឋានគ្រឹះក្នុងការបង្កើតកម្មវិធីសិក្សាសម្រាប់ការអប់រំដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន (សមត្ថភាពទាំងនេះនឹងត្រូវបានកំណត់បន្ថែមនៅក្នុងជំពូក ២ នៃការណែនាំនេះ)។

២. អន្តរកម្មរវាងនិស្សិតថែទាំវេជ្ជសាស្ត្រ ឬឆ្មប និងអតិថិជនគឺជាអាទិភាពសំខាន់នៃការអប់រំនិងការថែទាំប្រកបដោយគុណភាព(អតិថិជនត្រូវបានកំណត់ជាអ្នកទទួលការថែទាំពីអ្នកដែលមានវិជ្ជាជីវៈ)។

៣. វិធីសាស្ត្រអន្តរវិជ្ជាជីវៈចំពោះការអប់រំនិងការអនុវត្តមានសារៈសំខាន់ណាស់។

១.២.៥ ប្រធានបទសំខាន់ៗនៃស្តង់ដារពិភពលោករបស់ **WHO**

ឯកសារនេះត្រូវបានបែងចែកជា ៥ ប្រធានបទសំខាន់របស់ស្តង់ដារពិភពលោកសម្រាប់ការអប់រំថែទាំវេជ្ជសាស្ត្រ និងឆ្មប។ ខាងក្រោមនេះ នឹងសង្កត់ធ្ងន់តែចំពោះការអប់រំឆ្មប រីឯប្រធានបទសំខាន់ៗមានដូចខាងក្រោម៖

១. ការបញ្ចប់ការសិក្សា
២. ការអភិវឌ្ឍកម្មវិធី និងការពិនិត្យឡើងវិញ
៣. កម្មវិធីសិក្សា
៤. សាស្ត្រាចារ្យ
៥. ការចូលរៀន

១.២.៦ ស្តង់ដារពិភពលោកដែលបានចុះបញ្ជី

នៅក្នុងខ្លឹមសារនិងខ្លឹមសាររងនៃស្តង់ដារពិភពលោករបស់ WHO ដែលបានចុះបញ្ជីដូចខាងក្រោម៖

ប្រធានបទទី១. ការបញ្ចប់ការសិក្សា

ប្រធានបទនេះត្រូវបានបែងចែកទៅជាលទ្ធផលរងនិងគុណលក្ខណៈរង

លទ្ធផល

១.១.១ និស្សិតបញ្ចប់ការសិក្សាត្រូវមានសមត្ថភាព ក្នុងការអនុវត្តលើការថែទាំនិងឆ្មប។

១.១.២ និស្សិតបញ្ចប់ការសិក្សាបង្ហាញការយល់ដឹងត្រឹមត្រូវអំពីកត្តាកំណត់នៃសុខភាព។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

១.១.៣ និស្សិតបញ្ចប់ការសិក្សាផ្នែកថែទាំ ឬឆ្មបបានបំពេញគ្រប់បែបបទបទដ្ឋានគតិយុត្តដែលអនុញ្ញាតចុះឈ្មោះអាជីពជាគិលានុបដ្ឋាកឬឆ្មប។

១.១.៤ និស្សិតបញ្ចប់ការសិក្សាទទួលបានសញ្ញាប័ត្រជំនាញ។

១.១.៥ និស្សិតបញ្ចប់ការសិក្សាមានសិទ្ធិទទួលបានកម្មវិធីអប់រំកម្រិតខ្ពស់។

១.១.៦ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាក ឬឆ្មប ប្រើវិធីសាស្ត្រដើម្បីតាមដានភាពជោគជ័យនិងវឌ្ឍនភាពនៃការអប់រំរបស់និស្សិតក្រោយពីបញ្ចប់ការសិក្សា។

គុណលក្ខណៈ

១.២.១ និស្សិតបញ្ចប់ការសិក្សាផ្នែកគិលានុបដ្ឋាក ឬឆ្មបនឹងក្លាយជាអ្នកអនុវត្តដែលមានចំណេះដឹងនឹងប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងបទដ្ឋានវិជ្ជាជីវៈ។

១.២.២ សាលាបណ្ដុះបណ្ដាលគិលានុប្បដ្ឋាកឬឆ្មបត្រូវបញ្ចប់ការសិក្សានិស្សិតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- ផ្អែកលើភស្តុតាងក្នុងការអនុវត្តជាក់ស្តែង
- សមត្ថភាព
- សមត្ថភាពក្នុងការអនុវត្តក្នុងប្រព័ន្ធថែទាំសុខភាពនៃប្រទេសរៀងៗខ្លួននិងបំពេញសេចក្ដីត្រូវការរបស់ប្រជាជន
- ការគិតពិចារណានិងវិភាគ
- សមត្ថភាពក្នុងការគ្រប់គ្រងធនធាននិងការអនុវត្តប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព
- សមត្ថភាពក្នុងការធ្វើជាអ្នកតស៊ូមតិរបស់អតិថិជនប្រកបដោយប្រសិទ្ធភាព និងដៃគូដែលមានវិជ្ជាជីវៈដទៃទៀតក្នុងការផ្ដល់ការថែទាំសុខភាព
- អ្នកអប់រំសុខភាពដល់សហគមន៍
- សមត្ថភាពជាអ្នកដឹកនាំនិងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។

ប្រធានបទទី២. ការអភិវឌ្ឍកម្មវិធី និងការពិនិត្យឡើងវិញ

ប្រធានបទនេះ បានបែងចែកចំណងជើងជា អភិបាលកិច្ច ការទទួលស្គាល់គុណភាពអប់រំ ហេដ្ឋារចនាសម្ព័ន្ធនិងភាពជាដៃគូ។

អភិបាលកិច្ច

២.១.១ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាក ឬឆ្មប ត្រូវកំណត់និងផ្សព្វផ្សាយជាសាធារណៈនូវបេសកកម្ម ចក្ខុវិស័យ និងគោលបំណង។

២.១.២ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាក ឬឆ្មបបណ្ដុះបណ្ដាលនិស្សិតរបស់ខ្លួនស្របតាមកម្មវិធីសិក្សាដើម្បីបំពេញតំរូវការសុខភាពរបស់សង្គម។

២.១.៣ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបបានកំណត់យ៉ាងច្បាស់នូវលទ្ធផលអប់រំនិងគ្លីនិកនៃកម្មវិធីសិក្សា។

២.១.៤ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ផ្ដល់ការងារដល់គិលានុបដ្ឋាកឬឆ្មបដែលមានជំនាញពាក់ព័ន្ធ សមត្ថភាពក្នុងការអភិវឌ្ឍនិងកែប្រែកម្មវិធី។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

២.១.៥ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មាននិងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធនៃការវាយតំលៃជាផ្លូវការនិងបូកសរុបនៃកម្មវត្ថុនិងលទ្ធផលនៃការសិក្សានិងគ្លីនិក។

២.១.៦ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវកំណត់ការពិពណ៌នាតួនាទីសម្រាប់គគ្រូទ្រីស្ដីនិងគ្លីនិក ប៉ុន្ដែមិនត្រូវកំណត់ចំពោះគ្រូអ្នកណែនាំទេ ។

ការទទួលស្គាល់គុណភាពអប់រំ

២.២.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប គឺជាផ្នែកសំខាន់មួយនៃស្ថាប័នឧត្ដមសិក្សាដែលបំពេញតាមស្ដង់ដារផ្ទៃក្នុងការទទួលស្គាល់ឬតម្រូវការរបស់ស្ថាប័ន។

២.២.២ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានលក្ខណ:វិនិច្ឆ័យដែលត្រូវនឹងស្ដង់ដារទទួលស្គាល់សម្រាប់សមាសធាតុអនុវត្តគ្លីនិកនៃកម្មវិធីមាតិកាសិក្សានិងការបង្ហាញលទ្ធផលវិជ្ជាជីវ:។

២.២.៣ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប និងកម្មវិធីត្រូវបានទទួលស្គាល់ឬទទួលស្គាល់ដោយស្ថាប័នដែលមានជំនាញវិជ្ជាជីវៈនិងស្ថាប័នដែលអាចជឿទុកចិត្តបាននិងត្រូវបានទទួលស្គាល់ជាផ្លូវការឡើងវិញ។

ហេដ្ឋារចនាសម្ព័ន្ធ

២.៣.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានបរិក្ខារូបវ័ន្តដែលអាចចូលដំណើរការបានបច្ចុប្បន្ននិងពាក់ព័ន្ធរួមមាន បន្ទប់រៀន កន្លែងអនុវត្តគ្លីនិក បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ មន្ទីរពិសោធន៍ពិសោធន៍ និងបណ្ណាល័យ។

២.៣.២ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានប្រព័ន្ធនិងគោលនយោបាយដែលធានាសុវត្ថិភាពនិងសុខុមាលភាពរបស់និស្សិតនិងគ្រូ។

២.៣.៣ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានបុគ្គលិកគាំទ្រជំនាញនិងធនធានមនុស្សដើម្បីបំពេញតាមកម្មវិធីនិងតម្រូវការរបស់សិស្ស។

២.៣.៤ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានការបែងចែកថវិកានិងការគ្រប់គ្រងថវិកាដែលត្រូវនឹងកម្មវិធី គ្រូនិងនិស្សិត។

២.៣.៥ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានប្រព័ន្ធផ្ដល់សេវាកម្មគាំទ្រដល់និស្សិត។

ភាពជាដៃគូ

២.៤.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប បង្ហាញភាពជាដៃគូជោគជ័យជាមួយស្ថាប័ន សិក្សា មានកន្លែងអនុវត្តគ្លីនិកជាមួយអង្គការគ្លីនិក និងជាមួយដៃគូអន្តរជាតិ។

ប្រធានបទី៣. កម្មវិធីសិក្សា

ប្រធានបទនេះត្រូវបានបែងចែកទៅជា ការរចនាកម្មវិធីសិក្សា កម្មវិធីសិក្សាស្នូល ភាពជាដៃគូកម្មវិធីសិក្សា និងវាយតម្លៃនិស្សិត។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ការរចនាកម្មវិធីសិក្សា

៣.១.១ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប រចនាកម្មវិធីសិក្សានិងផ្ដល់កម្មវិធីដែលគិតគូរពីលំហូរផែនការការងារ និងគោលនយោបាយថែទាំសុខភាពថ្នាក់ជាតិនិងអន្តរជាតិ។

៣.១.២ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវរៀបចំផែនការ និងកម្មវិធីសិក្សាដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យការអប់រំថ្នាក់ជាតិនិងអន្តរជាតិ និងតម្រូវការជំនាញនិងបទប្បញ្ញត្តិសម្រាប់ការអនុវត្ត។

៣.១.៣ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវផ្ដល់នូវថ្នាក់រៀននិងគ្លីនិក ដែលផ្ដល់ចំណេះដឹង និងជំនាញដែលត្រូវការដើម្បីបំពេញសេចក្ដីត្រូវការរបស់ប្រជាជនរៀងៗខ្លួន។

៣.១.៤ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប បង្កើតនិងបង្ហាញតុល្យភាពរវាងទ្រឹស្ដីនិងសមាសធាតុអនុវត្តន៍នៃកម្មវិធីសិក្សា។

៣.១.៥ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវបង្ហាញការប្រើប្រាស់វិធីសាស្ត្រដែលត្រូវបានទទួលស្គាល់ក្នុងការបង្រៀននិងរៀននៅក្នុងកម្មវិធីសិក្សា ប៉ុន្តែមិនកំណត់ចំពោះការអប់រំមនុស្សពេញវ័យការតាមរយៈការរៀនដោយផ្ទាល់ ការរៀនតាមអេឡិចត្រូនិចនិងការពិសោធន៍គ្លីនិក។

៣.១.៦ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ផ្ដល់នូវថ្នាក់រៀននិងការសិក្សាគ្លីនិក ដោយផ្អែកលើសមត្ថភាពដែលបានបង្កើតឡើង និងផ្អែកលើភស្តុតាងបច្ចុប្បន្នដែលអាចជឿជាក់បានបំផុត។

៣.១.៧ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប អាចជួយអភិវឌ្ឍការវែកញែកខាងការព្យាបាលការដោះស្រាយបញ្ហា និងការគិតពិចារណាក្នុងកម្មវិធី។

៣.១.៨ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវធ្វើការវាយតម្លៃជាទៀងទាត់លើកម្មវិធីសិក្សានិងការសិក្សាគ្លីនិកហើយរួមមានការផ្ដល់យោបល់របស់និស្សិតអតីតជនអ្នកពាក់ព័ន្ធនិងដៃគូ។

៣.១.៩ កម្មវិធីសិក្សាគិលានុបដ្ឋាកឬឆ្មប ផ្ដល់ឱកាសសម្រាប់មាតិកាពហុមុខវិជ្ជា និងបទពិសោធន៍រៀនសូត្រ។

កម្មវិធីសិក្សាស្នូល

៣.២.១ កម្មវិធីសិក្សាថែទាំវេជ្ជសាស្ត្រ ឬឆ្មប ផ្ដល់នូវខ្លឹមសារសំខាន់ៗដែលអាចជួយឱ្យនិស្សិតបញ្ចប់ការសិក្សារបស់ពួកគេអាចបំពេញបានតាមសមត្ថភាពដែលបានបង្កើតឡើង។

៣.២.២ កម្មវិធីសិក្សាគិលានុបដ្ឋាក ផ្ដល់នូវខ្លឹមសារស្នូលនៅក្នុងទ្រឹស្ដីថែទាំ ការអនុវត្ត អន្តរាគមន៍និងវិសាលភាពនៃការអនុវត្ត។

៣.២.៣ កម្មវិធីសិក្សាឆ្មបផ្ដល់នូវខ្លឹមសារសំខាន់នៅក្នុងទ្រឹស្ដីឆ្មប ការអនុវត្តន៍ អន្តរាគមន៍ និងវិសាលភាពនៃការអនុវត្ត ពង្រឹងប្រព័ន្ធសុខាភិបាលតាមរយៈវិធីសាស្ត្រថែទាំសុខភាព។

៣.២.៤ កម្មវិធីគិលានុបដ្ឋាកឬឆ្មប ផ្ដល់នូវបទពិសោធន៍រៀនសូត្រគ្លីនិកដែលគាំទ្រដល់ទ្រឹស្ដីថែទាំឬឆ្មបក្នុងស្ថានភាពផ្សេងៗគ្នា។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ភាពជាដៃគូកម្មវិធីសិក្សា

៣.៣.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប បង្កើតភាពជាដៃគូសុខភាពផ្សេងទៀត។

៣.៣.២ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ប្រើវិធីសាស្ត្រការងារជាក្រុមដែលមានអន្តរវិជ្ជា ជីវៈក្នុងថ្នាក់រៀន និងបទពិសោធន៍គ្លីនិក។

៣.៣.៣ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានលទ្ធភាពទទួលនិងរៀបចំកន្លែងសិក្សា គ្លីនិកដែលត្រូវការសម្រាប់ការផ្ដល់កម្មវិធី។

ការវាយតម្លៃនិស្សិត

៣.៤.១ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវវាយតម្លៃការសិក្សារបស់និស្សិត ចំណេះដឹងនិងការអភិវឌ្ឍជំនាញ តាមរយៈកម្មវិធីសិក្សាដោយប្រើវិធីសាស្ត្រវាយតម្លៃដែលអាចទុកចិត្តបាន។

៣.៤.២ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ប្រើវិធីសាស្ត្រជាច្រើនដើម្បីវាយតម្លៃលើមុខវិជ្ជាដែលកំពុងសិក្សារួមមានការវាយតំលៃផ្អែកលើលទ្ធផលរបស់សិស្សនិងការឆ្លើយតបរបស់អតិថិជន និងភាគីពាក់ព័ន្ធ។

៣.៤.៣ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប មានប្រព័ន្ធរក្សានិស្សិត។

ប្រធានបទទី៤ អំពីសាស្ត្រាចារ្យ

ប្រធានបទនេះ ត្រូវបានបែងចែកជាអនុមុខវិជ្ជា បុគ្គលិកសិក្សា គ្រូគ្លីនិក និងការអភិវឌ្ឍវិជ្ជាជីវៈរបស់ សាស្ត្រាចារ្យ

បុគ្គលិកសិក្សា

៤.១.១ ប្រធានកម្មវិធីសិក្សាគិលានុបដ្ឋាកឬឆ្មប គឺជាគិលានុបដ្ឋាកឬឆ្មបដែលមានសញ្ញាប័ត្របញ្ចប់ការសិក្សាទទួលបានការអប់រំនិងបទពិសោធន៍ក្នុងភាពជាអ្នកដឹកនាំ និងរដ្ឋបាលហើយបង្ហាញចំណេះដឹងក្នុងនាមជាអ្នកអប់រំ។

៤.១.២ បុគ្គលិកសិក្សាសំខាន់ត្រូវតែជាគិលានុបដ្ឋាក និងឆ្មបដែលមានចំណេះដឹងក្នុងនាមជាអ្នកអប់រំនិងមានបរិញ្ញាបត្រអប្បបរមា - ជាសញ្ញាប័ត្រដែលបញ្ចប់ការសិក្សាមានជំនាញ។

៤.១.៣ ជំនាញសុខភាពផ្សេងទៀតដែលជាសាស្ត្រាចារ្យអញ្ជើញ ក្នុងកម្មវិធីថែទាំវេជ្ជសាស្ត្រ ឬឆ្មប ទទួលបានសញ្ញាបត្របញ្ចប់ការសិក្សានិងមានជំនាញគ្លីនិកនិងការអប់រំ។

គ្រូគ្លីនិក

៤.២.១ គ្រូគ្លីនិក រួមមានគិលានុបដ្ឋាកឆ្មបនិងវិជ្ជាជីវៈសុខភាពដទៃទៀត ដែលមានសញ្ញាបត្រពី សាកលវិទ្យាល័យនិងមានជំនាញខាងគ្លីនិក និងការអប់រំក្នុងជំនាញរបស់គេ។

៤.២.២ គិលានុបដ្ឋាកនិងឆ្មបដែលមានជំនាញផ្នែកគ្លីនិក កំពុងបង្រៀនត្រូវបានគេចាត់តាំងដើម្បីត្រួតពិនិត្យនិងបង្រៀននិស្សិតក្នុងជំនាញអនុវត្តគ្លីនិក។

៤.២.៣ សាលាបណ្ដុះបណ្ដាលគិលានុបដ្ឋាកឬឆ្មប ត្រូវបង្កើតភាពជាដៃគូដើម្បីធានាឱ្យមានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ធ្វើជាអ្នកត្រួតពិនិត្យគ្រូគ្លីនិកនិងគ្រូទ្រីះស្ដី។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកអប់រំ

៤.៣.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានគោលនយោបាយនិងប្រព័ន្ធដែលមាន សុពលភាពជំនាញគ្លីនិកនិងអ្នកជំនាញអប់រំ និងបុគ្គលិកអប់រំដែលមានសមត្ថភាព។

៤.៣.២ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានប្រព័ន្ធមួយដែលផ្ដល់ឱកាសដល់បុគ្គលិកអប់រំសម្រាប់ការអភិវឌ្ឍន៍ក្នុងការបង្រៀនអាហារូបករណ៍ ការអនុវត្តន៍និងសកម្មភាពវិជ្ជាជីវៈ។៤.៣.៣ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានប្រព័ន្ធនិងគោលនយោបាយត្រឹមត្រូវនិងផ្ដល់ពេលវេលានិងធនធានសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិក។

៤.៣.៤ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានគោលនយោបាយនិងប្រព័ន្ធដើម្បីទទួលបានរង្វាន់និងការទទួលស្គាល់បុគ្គលិកស្របតាមតម្រូវការសម្រាប់ការលើកកម្ពស់និងសិទ្ធិកាន់កាប់របស់ស្ថាប័ន។

ប្រធានបទទី៥ ការចុះឈ្មោះចូលរៀន

ប្រធានបទនេះ ត្រូវបានបែងចែកគោលការណ៍នៃការចុះឈ្មោះ និងជ្រើសរើសចូលរៀន

គោលការណ៍នៃការចុះឈ្មោះ និងជ្រើសរើសចូលរៀន

៥.១.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានគោលការណ៍ចូលរៀនប្រកបដោយតម្លាភាពដែលបញ្ជាក់ពីដំណើរការនៃការជ្រើសរើសនិស្សិតនិងលក្ខណៈវិនិច្ឆ័យទទួលយកអប្បបរមា។

៥.១.២ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានដំណើរការចូលនិងជ្រើសរើសមិនរើសអើងប្រកបដោយតម្លាភាព។

៥.១.៣ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានប្រព័ន្ធនិងគោលនយោបាយដែលត្រូវយកមកពិចារណាពីចំណុចចូលផ្សេងៗគ្នារបស់និស្សិត ការទទួលស្គាល់ការរៀន បទពិសោធន៍ និងការបន្តទៅឧត្តមសិក្សា។

៥.១.៤ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបមានលក្ខខណ្ឌចូលរៀនដែលស្របតាមលក្ខណៈវិនិច្ឆ័យថ្នាក់ជាតិសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ប៉ុន្តែមិនមានកំណត់ចំពោះការបញ្ចប់មធ្យមសិក្សាទេ។

ប្រភេទនិស្សិត និងការទទួលស្គាល់

៥.២.១ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបត្រូវទទួលស្គាល់និសរ្សិតមានបញ្ចប់ថ្នាក់វិទ្យាសាស្ត្រនិងគណិតវិទ្យានិងមានជំនាញភាសាក្នុងទាក់ទងជាមួយអតិថិជន។

៥.២.២ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបទទួលស្គាល់សិស្សដែលមានសមត្ថភាពបំពេញតាមតម្រូវការនៃកម្មវិធី។

៥.២.៣ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបទទួលយកនិស្សិតមានសុខភាពគ្រប់តាមលក្ខខណ្ឌរបស់សាលានិងតម្រូវការផ្សេងទៀតក៏ដូចជាតម្រូវការថ្នាក់ជាតិសម្រាប់ការជ្រើសរើស។

៥.២.៤ សាលាបណ្ឌុះបណ្ដាលគិលានុបដ្ឋាកឬឆ្មបស្វែងរកនិស្សិតដែលមានឆន្ទៈក្នុងការបម្រើសុខភាព និងសមត្ថភាពសិក្សាឯករាជ្យ។

១.៣ សេចក្ដីសង្ខេបស្តង់ដាររបស់ ICM និងការអនុវត្តន៍ស្តង់ដារល្អបំផុត WHO

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ខាងក្រោមនេះគឺជាការបូកសរុបនៃការអនុវត្តស្តង់ដារល្អបំផុត និងវិធីសាស្ត្រដែលបានពិពណ៌នានៅក្នុងឯកសារ ICM ដែលបានបង្ហាញក្នុងចំណុច១.១ និងឯកសាររបស់អង្គការសុខភាពពិភពលោកដែលបានបង្ហាញក្នុងចំណុច១.២ ។ ការសង្ខេបការអនុវត្តន៍ស្តង់ដារល្អបំផុត និងវិធីសាស្ត្រល្អបំផុតត្រូវបានដាក់នៅក្នុងបរិបទមូលដ្ឋាននៃបណ្តាប្រទេសដៃគូនៅពេលមានការសន្តថាពាក់ព័ន្ធ។ គោលបំណងនៃការបូកសរុបនេះគឺដើម្បីបង្ហាញពីទិដ្ឋភាពទូទៅនៃស្តង់ដារពិភពលោករបស់ ICM និងអង្គការសុខភាពពិភពលោក ដែលដើរតួជាមូលដ្ឋានគ្រឹះនៃរបាយការណ៍នេះក្នុងការអនុវត្តន៍ ស្តង់ដារល្អបំផុតសម្រាប់គម្រោង SafeMa បង្ហាញក្នុងចំណុច ១.៤។

ការបូកសរុបត្រូវបានបែងចែកជា ៣ ផ្នែកគឺការអនុវត្តល្អបំផុត ស្តង់ដារល្អបំផុត និងវិធីសាស្ត្រល្អ បំផុត។ ការអនុវត្តល្អបំផុតដែលមានក្នុងរបាយការណ៍នេះត្រូវបានកំណត់ការអប់រំឆ្មប ដែលទទួលយកនិងមានប្រសិទ្ធភាពបំផុត យោងទៅតាម ICM និងអង្គការសុខភាពពិភពលោក។ ស្តង់ដារល្អបំផុត ក្នុងរបាយការណ៍នេះត្រូវបានកំណត់ថាមានកំរិតស្តង់ដារក្នុងការអប់រំឆ្មប អាចទទួលយកបានយោងតាម ICM និងអង្គការសុខភាពពិភពលោក។ វិធីសាស្ត្រល្អបំផុតនៅក្នុងរបាយការណ៍នេះត្រូវបានកំណត់ជាប្រព័ន្ធល្អបំផុតនៃវិធីដើម្បីរៀបចំផែនការការអប់រំឆ្មប យោងតាម ICM និងអង្គការសុខភាពពិភពលោក។ នោះបីជាការបូកសរុបត្រូវបានបែងចែកជា ៣ ផ្នែកក៏ដោយការបែងចែកនេះអាចជាមានភាពលំអៀងព្រោះលក្ខខណ្ឌទាំងនេះមានលក្ខណៈខុសគ្នា។ ដូច្នេះការត្រួតគ្នាមួយចំនួននៅក្នុងផ្នែកទាំងបីនឹងត្រូវបានគេមើលឃើញ។

១.៣.១ ការអនុវត្តល្អបំផុត

នៅក្នុងសេចក្តីសង្ខេបនៃការអនុវត្តល្អបំផុតរបស់ ICM និង WHO ត្រូវបានពិពណ៌នានិងដាក់នៅក្នុងបរិបទក្នុងតំបន់នៃប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជា។ ការអនុវត្តល្អបំផុតដែលមានក្នុងរបាយការណ៍នេះត្រូវបានកំណត់ការអប់រំឆ្មប ដែលទទួលយកនិងមានប្រសិទ្ធភាពបំផុត យោងទៅតាម ICM និងអង្គការសុខភាពពិភពលោក។

១.៣.១.១ ការរៀនសូត្រនៅកន្លែងផ្សេងៗគ្នា

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំ និងដើម្បីជួយសម្រួលដល់ការរៀនសូត្រទាំងផ្នែកទ្រឹស្តីនិងជាក់ ស្តែង។ និស្សិតត្រូវមានបទពិសោធន៍អនុវត្តជាក់ស្តែងប្លែកគ្នាដើម្បីទទួលបានយ៉ាងហោចណាស់សមត្ថភាពបច្ចុប្បន្នរបស់ ICM សម្រាប់ការអនុវត្តឆ្មបមូលដ្ឋាន។

ការអប់រំឆ្មបគួរតែផ្តល់នូវបទពិសោធន៍ផ្នែកគ្លីនិកដែលគាំទ្រដល់ទ្រឹស្តីឆ្មបក្នុងវិស័យផ្សេងៗគ្នា។ ដើម្បីបំពេញលក្ខណៈវិនិច្ឆ័យនៃការអនុវត្តល្អបំផុតសម្រាប់ការសិក្សាអនុវត្តឆ្មបអោយបានសមស្របគួរតែត្រូវបានសរសេរនិងអនុវត្តឱ្យបានច្បាស់លាស់ និងត្រូវមានការត្រួតពិនិត្យជាបន្ត ហើយគ្រូទ្រឹស្តីឆ្មបគួរតែផ្តល់ការអប់រំការគាំទ្រនិងការត្រួតពិនិត្យបុគ្គលដែលបង្រៀននិស្សិតនៅទីតាំងសិក្សាជាក់ស្តែង។

សមាមាត្រនិស្សិតនិងគ្រូពេលធ្វើងគ្លីនិកគួរតែមិនលើសពី ១-២ នាក់ក្នុងមួយគ្រូគ្លីនិក ដូច្នេះនិស្សិតអាចផ្តល់ការថែទាំឆ្មបជាចម្បងក្រោមការត្រួតពិនិត្យរបស់គ្រូគ្លីនិក។

បរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូប្រទេសវៀតណាមនិងកម្ពុជាមានភាពពាក់ព័ន្ធនឹងសមាមាត្រនិស្សិតមិនត្រូវអោយលើសពី១-២នាក់ក្នុងគ្រូម្នាក់ដើម្បីធានានិស្សិតឆ្មបផ្តល់ការថែទាំដែលភាគច្រើនស្ថិតក្រោមការត្រួតពិនិត្យ

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

បស់គ្រូព្យាបាល។ ដូច្នេះការសិក្សា វានឹងសំរេចបាននូវសមត្ថភាពការអនុវត្តមូលដ្ឋានរបស់ ICM។

ក្នុងការធ្វើគ្លីនិក គ្រូបង្រៀនទ្រឹះស្តីនិងគ្រូគ្លីនិកឆ្មបគួរតែធ្វើការរួមគ្នាដើម្បីគាំទ្រនិងតាមដានដោយផ្ទាល់និងវាយតម្លៃការសិក្សាជាក់ស្តែងរបស់សិស្ស។

ក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាមនិងកម្ពុជា វាមានការពាក់ព័ន្ធរវាងការអប់រំ វិធីសាស្ត្រវាយតម្លៃ និងវាយតម្លៃត្រឹមត្រូវដែលអាចជឿទុកចិត្តបាន ដើម្បីវាស់វែងការអនុវត្តនិងការសិក្សារបស់និស្សិត ហើយទាំងនេះត្រូវបានសរសេរនិងចែករំលែកជាមួយនិស្សិត។

១.៣.១.២ ការចូលរួមរបស់និស្សិតក្នុងការកែលំអគុណភាព

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវការលើកទឹកចិត្តដល់និស្សិតឱ្យចូលរួមយ៉ាងសកម្មក្នុងការកែលំអគុណភាពកម្មវិធីសិក្សា។ ដើម្បីបំពេញបាននូវការអនុវត្តល្អបំផុត ត្រូវមាននគោលនយោបាយស្តីពីនិស្សិត និងរួមបញ្ចូលទាំងយន្តការដូចជាការវាយតំលៃផ្អែកលើលទ្ធផលនិងការឆ្លើយតបរបស់អតិថិជន សម្រាប់និស្សិតត្រូវផ្តល់នូវមតិយោបល់ដែលជាធាតុចូល និងការវាយតំលៃបន្តនៃកម្មវិធីសិក្សាឆ្មប បុគ្គលិកអប់រំ និងកម្មវិធីឆ្មប ហើយគួរតែមានឱកាសសម្រាប់ សិស្សឱ្យចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីអភិបាលកិច្ចនិងគណ:កម្មាធិការកម្មវិធីឆ្មប។

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជា វាជាការពាក់ព័ន្ធជាមួយការអប់រំឆ្មបដែលមានយន្តការផ្តល់យោបល់ត្រឡប់សំរាប់ការវាយតម្លៃបន្តនៃការអប់រំឆ្មប។ ការយកចិត្តទុកដាក់ជាពិសេសគួរតែជាការផ្តល់ឱកាសនិស្សិតក្នុងការចូលរួមក្នុងកម្មវិធីអភិបាលកិច្ចនិងគណ:កម្មការឆ្មបដើម្បីជាការលើកទឹកចិត្តដល់ការចូលរួមរបស់និស្សិតក្នុងការលើកកម្ពស់គុណភាព។ នេះក៏អាចលើកទឹកចិត្តនិស្សិតឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការកែលម្អគុណភាពនិងការអភិវឌ្ឍគោលការណ៍ណែនាំបន្ទាប់ពីបញ្ចប់ការសិក្សា។ របាយការណ៍ពីក្រសួងសុខាភិបាលនៃប្រទេសវៀតណាម បានបង្ហាញពីការចូលរួមរបស់ឆ្មបដែលមានកំណត់ក្នុងការកំណត់គោលការណ៍ណែនាំនិងបទបញ្ញត្តិជាក់លាក់របស់ឆ្មបហើយដូច្នេះទស្សនៈរបស់ពួកគេមិនត្រូវបានឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់ទេ (៧ ទំព័រ ១៨)។

១.៣.១.៣. ការអនុវត្តជាក់ស្តែងដែលផ្អែកលើការគិតត្រិះរិះពិចារណា

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវការប្រើប្រាស់វិធីសាស្ត្រការអនុវត្តជាក់ស្តែងក្នុងការបង្រៀននិងរៀន។ ដើម្បីបំពេញតាមស្តង់ដានេះ ការអប់រំឆ្មបត្រូវការផ្តល់ថ្នាក់រៀននិងរៀនតាមគ្លីនិកដោយផ្អែកលើសមត្ថភាពនិងការអនុវត្តជាក់ស្តែងបច្ចុប្បន្នដែលអាចទុកចិត្តបានបំផុត។ ការអប់រំឆ្មបចាំបាច់ត្រូវយកចិត្តទុកដាក់ជាពិសេសដើម្បីជួយដល់ការអភិវឌ្ឍនៃហេតុផលនៃការអនុវត្តគ្លីនិកការដោះស្រាយបញ្ហាការគិតពិចារណា និងការគិតវិភាគ។

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូប្រទេសវៀតណាម និងកម្ពុជា ជាការពាក់ព័ន្ធការអប់រំឆ្មបក្នុងថ្នាក់រៀន និងការសិក្សាគ្លីនិកគឺផ្អែកលើភ័ស្តុតាងបច្ចុប្បន្ន

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

និងគួរឱ្យទុកចិត្តបំផុតហើយគ្រូគួរប្រើគរុកោសល្យក្នុងការលើកទឹកចិត្តដល់ប្រើហេតុផលក្នុងធ្វើក្លីនិងការដោះស្រាយបញ្ហា ការ ត្រិះរិះពិចារណា និងការគិតវិភាគ។

១.៣.១.៤. គ្រប់គ្រងធនធាននិងការអនុវត្តដើម្បីឆ្លើយតបតម្រូវការប្រជាជន

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មបនិស្សិតមានសមត្ថភាពក្នុងការអនុវត្តក្នុងប្រព័ន្ធថែទាំសុខភាពនៃប្រទេសរៀងៗខ្លួននឹងបំពេញតម្រូវការថែទាំសុខភាពរបស់ប្រជាជនក្នុងតំបន់របស់ពួកគេ។ ដើម្បីបំពេញតាមស្តង់ដារនេះ: ការអប់រំឆ្មបគួរពិចារណាទាំងគោលនយោបាយនិងស្តង់ដារជាតិនិងអន្តរជាតិដើម្បីឆ្លើយតបនឹងតម្រូវការកម្លាំងពលកម្មមាតុភាព។

ការអប់រំឆ្មបគួរតែរៀបចំឱ្យនិស្សិតបញ្ចប់ការសិក្សាដែលមានសមត្ថភាពនិងមានសមត្ថភាពអនុវត្តនៅក្នុងប្រព័ន្ធថែទាំសុខភាពនៃប្រទេសរៀងៗខ្លួនដើម្បីគ្រប់គ្រងធនធាននិងអនុវត្តប្រកបដោយសុវត្ថិភាពប្រសិទ្ធភាពដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជន។

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាមនិងកម្ពុជាជាការពាក់ព័ន្ធការបង្រៀននិស្សិតក្នុងការអនុវត្តស្របតាមតម្រូវការរបស់ប្រជាជននៅក្នុងបរិបទក្នុងស្រុករបស់ពួកគេហើយពួកគេត្រូវបានបង្រៀនឱ្យបង្ហាញពីសមត្ថភាព។ បណ្តាប្រទេសជាដៃគូវាហាក់ដូចជាមានភាពខុសគ្នាច្រើននៅក្នុងតម្រូវការរបស់ប្រជាជននៅក្នុងតំបន់ទីក្រុងនិងជនបទនៃប្រទេសជាដៃគូដោយជនជាតិភាគតិចងាយរងគ្រោះជាពិសេស (៨) ។

១.៣.១.៥ ការរៀនពីក្រមសីលធម៌

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មបត្រូវអប់រំដល់និស្សិតឱ្យក្លាយជាអ្នកអនុវត្តដែលមានចំណេះដឹងដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងស្តង់ដារវិជ្ជាជីវៈរបស់ ICM។ នេះរួមបញ្ចូលទាំងសមត្ថភាពក្នុងការគាំទ្រអតិថិជនប្រកបដោយប្រសិទ្ធភាព។

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាមនិងកម្ពុជាមានភាពពាក់ព័ន្ធក្នុងការបញ្ជាក់ថានិស្សិតឆ្មបមានភាពស៊ីជម្រៅជាមួយនឹងក្រមសីលធម៌និងស្តង់ដារវិជ្ជាជីវៈរបស់ICM ជាពិសេសសង្កត់ធ្ងន់លើការគោរពសិទ្ធិមនុស្ស។ និយមន័យបន្ថែមទៀត អាចរកបាននៅក្នុងជំពូកទី ៣ នៃរបាយការណ៍នេះ។ របាយការណ៍ពីក្រសួងសុខាភិបាលវៀតណាមបានបង្ហាញថាការថែទាំប្រកបដោយការគោរព
និងលើកស្ទួយសិទ្ធិរបស់ស្ត្រីក្នុងការប្រើប្រាស់សេវាឆ្មបនៅតែមានភាពទន់ខ្សោយនៅក្នុងផ្នែកខ្លះ។ (៧)

១.៣.១.៦ ការអនុវត្តអន្តរវិជ្ជាជីវៈ

យោងទៅតាមគោលការណ៍របស់អង្គការសុខភាពពិភពលោក (សូមមើល ១.២.៤) អន្តរវិជ្ជាជីវៈចំពោះការអប់រំ និងការអនុវត្តមានសារៈសំខាន់ណាស់។ ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មបត្រូវការអប់រំដែលផ្តល់ខ្លឹមសារដែលមានពហុបទពិសោធន៍និងបទពិសោធន៍រៀនសូត្រដែលបំពេញបន្ថែមមាតិកាឆ្មប។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union

ដើម្បីបំពេញបាននូវការអនុវត្តន៍ល្អបំផុត ការអប់រំឆ្មបគួរតែប្រើវិធីសាស្ត្រអន្តរវិជ្ជាជីវៈជាក្រុមនៅក្នុងថ្នាក់រៀន និងបទពិសោធន៍នៃការសិក្សាគ្លីនិក។

នៅក្នុងបរិបទមូលដ្ឋាននៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជា ជាការពាក់ព័ន្ធដើម្បីបញ្ជាក់ថាការអប់រំឆ្មបប្រើវិធីសាស្ត្រអន្តរវិជ្ជាជីវៈជាក្រុមនៅក្នុងថ្នាក់រៀន និងបទពិសោធន៍នៃការសិក្សាគ្លីនិក។

១.៣.២ ស្តង់ដារល្អបំផុត

នៅក្នុងការបូកសរុបនៃ ICM និង WHO ដែលបានពិពណ៌នាអំពីស្តង់ដារល្អបំផុតនិងបានដាក់បញ្ចូលក្នុងបរិបទមូលដ្ឋាននៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងប្រទេសកម្ពុជា។ ស្តង់ដារល្អបំផុតត្រូវបានកំណត់កំរិតស្តង់ដារនៅក្នុងការអប់រំឆ្មបដែលត្រូវបានគេគិតថាអាចទទួលយកបានយោងទៅតាម ICM និង WHO។

១.៣.២.១ លក្ខខណ្ឌការចូលរៀន

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវមានគោលការណ៍សរសេរជាលាយលក្ខណ៍អក្សរ និងមានតម្លាភាពដែលអាចទទួលយកបានសម្រាប់បេក្ខជនដែលមានសក្តានុពល។ បេក្ខជនឆ្មបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គួរតែត្រូវបានទទួលស្គាល់ដោយគ្មានការរើសអើង ភេទ អាយុ ជាតិសាសន៍ និងសាសនា។

ដើម្បីស្របតាមស្តង់ដារល្អបំផុត គោលនយោបាយចូលរៀនគួរតែរួមបញ្ចូលនូវតម្រូវការចូលដែលបានកំណត់រួមទាំងតម្រូវការអប្បបរមានៃការបញ្ចប់ការសិក្សានៅមធ្យមសិក្សា និងដំណើរការជ្រើសរើស និងលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលនិស្សិតដែលមានសមត្ថភាពក្នុងការបំពេញតាមតម្រូវការរបស់កម្មវិធី។ គួរតែមានប្រព័ន្ធ និងគោលនយោបាយមួយដែលត្រូវយកមកពិចារណាពីចំណុចចូលផ្សេងគ្នារបស់និស្សិត ការទទួលស្គាល់នូវជម្រើសអាទិភាព បទពិសោធន៍ និងជម្រើសរបស់ពួកគេឆ្ពោះទៅរកគោលដៅឧត្តមសិក្សា។

ក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជា ការអប់រំឆ្មបត្រូវមានគោលនយោបាយចូលរៀនប្រកបដោយតម្លាភាព ហើយបេក្ខជនដែលមានសិទ្ធិទទួលបាន ការទទួលស្គាល់ដោយគ្មានការរើសអើង។

១.៣.២.២ ការបញ្ចប់ការសិក្សា

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប គោលបំណងនៃការអប់រំគឺការផលិតនិស្សិតដែលមានសមត្ថភាព។

ឆ្មបមានសមត្ថភាពត្រូវបានកំណត់ជាមនុស្សដែលបានឈានដល់កំរិតអប្បបរមានូវសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបមូលដ្ឋានរបស់ ICM (៤) និងជាអ្នកអនុវត្តស្វយ័តស្វយ័តដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌អន្តរជាតិសំរាប់ឆ្មប (៩)។ ស្តង់ដារវិជ្ជាជីវៈ និងវិសាលភាពនៃការអនុវត្តដែលបានបង្កើតឡើងនៅក្នុងដែនសមត្ថកិច្ចដែលមានការទទួលស្គាល់ស្របច្បាប់។ ដើម្បីបំពេញតាមស្តង់ដារល្អបំផុត

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

និស្សិតដែលបញ្ចប់ការសិក្សាក៏ត្រូវបង្ហាញពីសមត្ថភាពដែលបានបង្កើតឡើងនៅក្នុងការអនុវត្តឆ្មបនិងការយល់ដឹងឱ្យបានច្បាស់អំពីកត្តាកំណត់សុខភាព។ និស្សិតដែលបញ្ចប់ការសិក្សាចាំបាច់ត្រូវបំពេញតាមស្តង់ដាដើម្បីទទួលបានការចុះបញ្ជីអាជីពជាឆ្មបហើយមានសិទ្ធិដាក់ពាក្យសុំការអប់រំកម្រិតខ្ពស់។

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជាមានការពាក់ព័ន្ធនឹងការបញ្ចប់ការសិក្សាផ្នែកឆ្មបដែលទទួលបាននិងបង្ហាញសមត្ថភាពបច្ចុប្បន្នស្របតាមសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបមូលដ្ឋាននិងជាចំណេះដឹងរបស់ ICM។ ចំណេះដឹងនិងស្វ័យភាពដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌អន្តរជាតិសំរាប់ឆ្មប ស្តង់ដារនៃវិជ្ជាជីវៈនិងវិសាលភាពនៃការអនុវត្តបានបង្កើតឡើងក្នុងយុត្តាធិការដែលមានការទទួលស្គាល់ជាផ្លូវការ។ ការយកចិត្តទុកដាក់ពិសេសចំពោះភាពខុសគ្នានៃកម្រិតអប់រំរបស់ឆ្មបក្នុងវិជ្ជាជីវៈឆ្មបនៃប្រទេសដៃគូមានវៀតណាមនិងកម្ពុជាចាប់ពីការអប់រំមានកម្រិតក្នុងវិជ្ជាជីវៈរហូតដល់ការអប់រំនៅកម្រិតសាកលវិទ្យាល័យ (៧.១០)។

១.៣.៣ វិធីសាស្រ្តល្អបំផុត

ក្នុងការបូកសរុបខាងក្រោមនេះជាវិធីសាស្ត្រល្អបំផុតរបស់ ICM និងWHO ត្រូវបានពិពណ៌នា និងដាក់ក្នុងបរិបទមូលដ្ឋាននៃបណ្តាប្រទេសជាដៃគូមានវៀតណាម និងកម្ពុជា។ វិធីសាស្ត្រល្អបំផុតនៅក្នុងរបាយការណ៍នេះត្រូវបានកំណត់ ជាប្រព័ន្ធល្អបំផុតដើម្បីរៀបចំផែនការការអប់រំឆ្មប យោងទៅតាមរបស់ ICM និងអង្គការសុខភាពពិភពលោក។

១.៣.៣.១ ទស្សនវិជ្ជានៃកម្មវិធីអប់រំឆ្មប

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មបគួរតែកំណត់និងបង្ហាញជាសាធារណៈនូវទស្សនវិជ្ជានៃកម្មវិធី។ ទស្សនវិជ្ជានៃការអប់រំឆ្មបចាំបាច់ត្រូវស្របជាមួយទស្សនវិជ្ជា ICM និងគំរូនៃការថែទាំ។ ដើម្បីស្របតាមស្តង់ដារនៃវិធីសាស្ត្រល្អបំផុត គួរតែមានទស្សនវិជ្ជាជាលាយលក្ខណ៍អក្សរដែលពិពណ៌នាអំពីជំនឿរបស់កម្មវិធី អំពីការបង្រៀននិងការរៀនសូត្រនិងការថែទាំឆ្មប។ ជំនឿលើការបង្រៀន និងការរៀនអាចរួមទាំងការផ្តល់យោបល់របស់ ICMពីស្តង់ដារ ១.៤៖

- កំរិតនិងប្រភេទនៃអ្នកសិក្សា
- ទ្រឹស្តីអប់រំ
- ទំនាក់ទំនងគួរឱ្យគោរពរវាងគ្រូនិងអ្នករៀន
- បរិយាកាសនៃការសិក្សា
- ជំនឿ
- ភាពជាដៃគូជាមួយស្ត្រី
- ការផ្តល់អំណាចដល់ស្ត្រី
- ការថែទាំបុគ្គល / ផ្ទាល់ខ្លួន
- ការបន្តថែទាំ
- ភាពធម្មតានៃការមានផ្ទៃពោះនិងកំណើត
- ការថែទាំប្រកបដោយសុវត្ថិភាពស្របតាមបទដ្ឋាន
- សុវត្ថិភាពវប្បធម៌
- សិទ្ធិមនុស្ស

ក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជាមានការពាក់ព័ន្ធ ទស្សនវិជ្ជាដែលត្រូវបានរៀបចំជាលាយលក្ខណ៍អក្សរហើយពិពណ៌នាអំពីជំនឿរបស់កម្មវិធី អំពីការបង្រៀននិងការរៀន

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union

ប្រសិនបើទស្សនវិជ្ជានៃការអប់រំនេះស្របជាមួយទស្សនវិជ្ជានិង ICM និងគំរូនៃការថែទាំ។ ការយកចិត្តទុកដាក់ពិសេស លើទស្សនវិជ្ជានៃការបង្រៀន និងការរៀនផ្អែកលើសមត្ថភាពនិងការអនុវត្តជាក់ស្តែង និងការគោរពសិទ្ធិមនុស្ស។

១.៣.៣.២ លក្ខខណ្ឌកំណត់គ្រូ និងគ្រូគ្លីនិក

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប តម្រូវអោយគ្រូនិងគ្រូគ្លីនិកដែលមានជំនាញឆ្មបលើសលុប ដែលធ្វើការជាមួយអ្នកជំនាញមកពីវិស័យផ្សេងដោយមានជំនាញពាក់ព័ន្ធតាមតម្រូវការ។

ដើម្បីស្របតាមស្តង់ដារល្អបំផុត គួរតែមានការរៀបចំជាផ្លូវការក្នុងការផ្តល់ចំណេះដឹងក្នុងនាមជាអ្នកអប់រំនិងមានបរិញ្ញាបត្រអប្បបរមា។

គ្រូឆ្មបគួរតែមានសមត្ថភាពក្នុងការអនុវត្ត រយៈពេលយ៉ាងតិច ២ឆ្នាំ។ ប្រធានកម្មវិធីសិក្សាឆ្មប គួរតែជាគ្រូបង្រៀនឆ្មបដែលមានសមត្ថភាពនិងមានបទពិសោធន៍ក្នុងការគ្រប់គ្រងនិងរដ្ឋបាល។ គ្រូឆ្មបគួរតែគ្រប់គ្រងខ្លួនឯងនិងទទួលខុសត្រូវក្នុងការអភិវឌ្ឍ ដឹកនាំគោលនយោបាយ និងកម្មវិធីសិក្សា។ ប្រសិទ្ធភាពគ្រូឆ្មប គួរតែត្រូវបានវាយតម្លៃជាប្រចាំបន្ទាប់ពីដំណើរការវាយតម្លៃដែលបានបង្កើត ឡើង។

ក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជាមានភាពពាក់ព័ន្ធពីសមត្ថភាពក្នុងការអនុវត្ត ដែលមានវិសាលភាពនៃការអនុវត្តរយៈពេល ២ ឆ្នាំពេញ និងប្រសិទ្ធភាពនៃសមាជិកគ្រូពេទ្យជំនាញឆ្មបត្រូវបានគេវាយតម្លៃជាប្រចាំ។

ការយកចិត្តទុកដាក់ជាពិសេសចំពោះបញ្ហាប្រឈមក្នុងការទទួលបានបុគ្គលិកអប់រំដែលមានសមត្ថភាពដូចរបាយការណ៍របស់ក្រសួងសុខាភិបាលនៃប្រទេសវៀតណាមបានបង្ហាញថាមានបញ្ហាដែលមានកម្រិតជំនាញទាបរបស់គ្រូបង្រៀននិងគ្រូបង្រៀនឆ្មប(៧ ទំព័រ ១៧)។

១.៣.៣.៣ ការអភិវឌ្ឍកម្មវិធីសិក្សា

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប គួរតែបង្កើតនិងបង្ហាញតុល្យភាពរវាងទ្រឹស្តីនិងសមាសធាតុអនុវត្តន៍នៃកម្មវិធីសិក្សា។ កម្មវិធីសិក្សាឆ្មបគួរតែមានទាំងទ្រឹស្តី និងអនុវត្តដែលមានទ្រឹស្តីអប្បបរមា ៤០ភាគរយ និងការអនុវត្តអប្បបរមា ៥០ភាគរយ។ លំដាប់លំដោយនិងខ្លឹមសារនៃកម្មវិធីសិក្សាឆ្មបគួរតែជួយឱ្យនិស្សិតទទួលបាននូវសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបស្របតាមឯកសារស្នូលរបស់ICM។

ក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជានឹងមានភាពពាក់ព័ន្ធពីតុល្យភាព រវាងទ្រឹស្តីនិងធាតុអនុវត្ត ដោយមានទ្រឹស្តីអប្បបរមា ៤០ ភាគរយនិងការអនុវត្តអប្បបរមា ៥០ ភាគរយ។

១.៣.៣.៤ ធនធាននិងឧបករណ៍សម្រាប់ការសិក្សា

ដើម្បីលើកកម្ពស់ឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវការឱ្យមានសម្ភារៈរូបវន្តដែលអាចចូលដំណើរការនិងប្រើប្រាស់បាន ប៉ុន្តែមិនមានកំណត់ចំពោះថ្នាក់រៀន កន្លែងអនុវត្តគ្លីនិក បច្ចេកវិទ្យាព័ត៍មាននិងគមនាគមន៍ មន្ទីរពិសោធន៏គ្លីនិកនិងឧបករណ៍សម្ភារៈដើម្បីទ្រទ្រង់ការរៀនសូត្រ ជាក់ស្តែងរបស់និស្សិតដូចជា ស្រោមដៃ ឧបករណ៍មន្ទីរពិសោធន៍ ដែលត្រូវបានបំពាក់ដើម្បីគាំទ្រវិទ្យាសាស្ត្រមូលដ្ឋាននិងការអភិវឌ្ឍជាក់ស្តែង និងបណ្ណាល័យ ជាមួយសៀវភៅសិក្សាទាន់សម័យ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

នៅក្នុងបរិបទក្នុងតំបន់នៃបណ្តាប្រទេសជាដៃគូមានប្រទេសវៀតណាម និងកម្ពុជា ជាការពាក់ព័ន្ធក្នុងការធានាថាសម្ភារៈនិងឧបករណ៍រូបវន្តដែលអាចរកបានមានដូចជាឧបករណ៍សម្រាប់សេវាឆ្មបគឺអាចរកបានមិនស្មើគ្នានៅកម្រិតមូលដ្ឋាននៅក្នុងប្រទេសជាដៃគូ (៧ ទំព័រ ១៧) ១០ ទំ: ១៤) ។

១.៤ គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព

គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព ក្នុងការអប់រំឆ្មបត្រូវបានបង្ហាញនៅទីនេះ។ គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាពក្នុងការអប់រំឆ្មបត្រូវបានកាត់ចេញពីស្តង់ដាពិភពលោក ICM និង WHO ដែលបង្ហាញក្នុង ១.១.០ និង ១.២.០ ហើយសង្ខេបនៅក្នុង ១.៣.០ ហើយឯកសារទាំងនេះ

ត្រូវបានដាក់នៅក្នុងបរិបទនៃបរិបទមូលដ្ឋាននៃបណ្តាប្រទេសដៃគូនៃប្រទេសវៀតណាម និងប្រទេសកម្ពុជា។

គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព នឹងបម្រើជាមគ្គុទេសក៍សម្រាប់ការវិភាគគំលាត WP1 task 2 ហើយនឹងត្រូវបានបង្ហាញក្នុងកំឡុងពេលប្រជុំគម្រោង។

គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព បានគោរពយ៉ាងពេញលេញទៅនឹងគោលបំណងរបស់អង្គការសុខភាពពិភពលោក“ពង្រឹងគុណភាពក្នុងរបាយការណ៍កិច្ចប្រជុំអប់រំឆ្មប (១១) ដោយផ្តោតពិសេសលើគោលដៅលេខទី ៨ នៃផែនការសកម្មភាពរយៈពេលវែងដែលសង្កត់ធ្ងន់លើវិធីសាស្ត្រដែលផ្អែកលើការគោរពសិទ្ធិមនុស្ស ដើម្បីធ្វើឱ្យប្រសើរឡើងនៅក្នុងការអប់រំឆ្មបអោយស្របតាមតម្រូវការ។ វិធីសាស្ត្ររបស់ SafeMa នឹងសិទ្ធិមនុស្សក្នុងការអប់រំឆ្មបត្រូវបានបង្ហាញនៅក្នុងជំពូកទី ៣ នៃរបាយការណ៍នេះ។ អង្គការសុខភាពពិភពលោកក៏មានគោលបំណងពង្រឹងការអប់រំឆ្មបផ្អែកលើភស្តុតាងជាក់ស្តែង។ វិធីសាស្ត្ររបស់ SafeMa ចំពោះការអប់រំឆ្មបដែលមានមូលដ្ឋាននៅក្នុងវិធីសាស្ត្រផ្អែកលើភស្តុតាងអាចរកឃើញនៅក្នុងជំពូកទី ៤ នៃរបាយការណ៍នេះ។

គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព បានអនុវត្តយ៉ាងពេញលេញទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ៣ (១២) ដែលគម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាពអាចចូលរួមចំណែកដល់គោលដៅ ៣.C របស់អង្គការសហប្រជាជាតិស្តីពីការបង្កើនការអភិវឌ្ឍនិងបណ្តុះបណ្តាលការថែទាំសុខភាពផ្ទាល់ខ្លួននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដោយធានានិង គុណវុឌ្ឍិនៃការប្តេជ្ញាចិត្តរបស់ SafeMa ដើម្បីឧត្តមភាពក្នុងការអភិវឌ្ឍវគ្គសិក្សាក្រោយឧត្តមសិក្សារបស់ SafeMa ។

នៅក្នុងគម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាព ត្រូវបានបង្ហាញជាចំណុចៗ។

១.៤.១ ចំណុចស្នូលរបស់ SafeMa

គម្រោង SafeMa ឆ្ពោះទៅរកឧត្តមភាពក្នុងការអប់រំឆ្មប បានស្ថិតក្នុងតារាងខាងក្រោម ដោយយោងទៅលើកន្លែងដែលអាចរកឃើញចំណុចលម្អិតបន្ថែមទៀត៖

១. ការសិក្សានៅទីតាំងផ្សេងៗគ្នា

ដើម្បីផ្តល់នូវឧត្តមភាពក្នុងការអប់រំឆ្មប
ការការអប់រំត្រូវបានជួយសម្រួលដល់ការរៀនសូត្រទាំងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែ។ សមាមាត្រនិស្សិត និងគ្រូនៅក្នុងគ្លីនិកគួរតែមិនលើសពី ១-២ នាក់ក្នុងមួយគ្រូគ្លីនិក។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.១.១ នៃរបាយការណ៍នេះ។

២. ការចូលរួមរបស់និស្សិតក្នុងការកែលំអគុណភាព

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំឆ្មប ការការអប់រំត្រូវការការលើកទឹកចិត្តដល់និស្សិតឱ្យចូលរួមយ៉ាងសកម្មក្នុងការកែលំអគុណភាពកម្មវិធីសិក្សា។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.១.២ នៃរបាយការណ៍នេះ។

៣. ការអនុវត្តជាក់ស្តែងផ្អែកលើការគិតត្រិះរិះពិចារណា

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវការការប្រើប្រាស់វិធីសាស្ត្រដែលមានភស្តុតាងជាក់ស្តែងក្នុងការបង្រៀន និងការរៀនដែលផ្អែកលើការគិតត្រិះរិះពិចារណា។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.១.៣ នៃរបាយការណ៍នេះ។

៤. ការគ្រប់គ្រងធនធាននិងការអនុវត្តដើម្បីឆ្លើយតបតម្រូវការប្រជាជន

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំផ្នែកឆ្មប ត្រូវការអប់រំនិស្សិតឱ្យមានសមត្ថភាពអនុវត្តក្នុងប្រព័ន្ធថែទាំសុខភាពនៃប្រទេសរៀងៗខ្លួន និងដើម្បីបំពេញតំរូវការថែទាំសុខភាពរបស់ប្រជាជនក្នុងតំបន់។ ចំណុចស្នូលនេះត្រូវបានពន្យល់បន្ថែមនៅក្នុងផ្នែកទី ១.៣.១.៤ នៃរបាយការណ៍នេះ។

៥. រៀនពីសីលធម៌

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំឆ្មប ការអប់រំនិស្សិតឱ្យក្លាយជាអ្នកអនុវត្តដែលមានចំណេះដឹងដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងស្តង់ដារវិជ្ជាជីវៈរបស់ ICM។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.១.៥ នៃរបាយការណ៍នេះ។

៦. ការអនុវត្តអន្តរវិជ្ជាជីវៈ

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំឆ្មប ការអប់រំត្រូវផ្តល់ជូននូវខ្លឹមសារពហុបទពិសោធន៍ និងបទពិសោធន៍រៀនសូត្រដែលបំពេញបន្ថែមមាតិកាឆ្មប។ ចំណុចស្នូលនេះត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.១.៥ នៃរបាយការណ៍នេះ។

៧. តម្រូវការជាផ្លូវការសម្រាប់ការចូលរៀន

ដើម្បីធ្វើឱ្យឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវការចាំបាច់មានគោលការណ៍សរសេរជាលាយលក្ខណ៍អក្សរ និងមានតម្លាភាពដែលអាចទទួលយកបានសម្រាប់បេក្ខជនដែលមានសក្តានុពល។ បេក្ខជនឆ្មបដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គួរតែត្រូវបានទទួលយកដោយគ្មានការរើសអើង។ ចំណុចស្នូលនេះ ត្រូវបានបញ្ជាក់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.២.១ នៃរបាយការណ៍នេះ។

៨. ការបញ្ចប់ការសិក្សា

ដើម្បីផ្តល់ឧត្តមភាពក្នុងការអប់រំឆ្មប គោលបំណងនៃការអប់រំគួរតែផលិតឆ្មបដែលមានសមត្ថភាព។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.២.២ នៃរបាយការណ៍នេះ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៩. ទស្សនវិជ្ជានៃកម្មវិធីអប់រំឆ្មប

ដើម្បីធ្វើឱ្យឧត្តមភាពនៃការអប់រំឆ្មប គួរតែត្រូវបានកំណត់និងបង្ហាញជាសាធារណៈនូវទស្សនវិជ្ជានៃកម្មវិធី និងទស្សនវិជ្ជានៃការអប់រំឆ្មបចាំបាច់ត្រូវស្របនឹងទស្សនវិជ្ជានិងគំរូនៃការថែរក្សាឆ្មបICM ។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.៣.១ នៃរបាយការណ៍នេះ។

១០. លក្ខខណ្ឌជ្រើសរើសបុគ្គលិកអប់រំ និងគ្រូគ្លីនិក

ដើម្បីធ្វើឱ្យឧត្តមភាពនៃការអប់រំឆ្មប ត្រូវមានគ្រូដែលមានជំនាញឆ្មបច្រើនលើសលុប និងធ្វើការជាមួយអ្នកជំនាញមកពីវិស័យដទៃទៀតដោយមានជំនាញពាក់ព័ន្ធតាមតម្រូវការ។ ចំណុចស្នូលនេះត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.៣.២ នៃរបាយការណ៍នេះ។

១១. ការអភិវឌ្ឍកម្មវិធីសិក្សា

ដើម្បីធ្វើឱ្យឧត្តមភាពនៃការអប់រំឆ្មប គួរតែបង្ហាញពីតុល្យភាពរវាង ទ្រឹស្តី និងសមាសធាតុអនុវត្តនៃកម្មវិធីសិក្សាដែលមានទ្រឹស្តីអប្បបរមា ៤០ ភាគរយនិងការអនុវត្តអប្បបរមា ៥០ ភាគរយ។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.៣.៣ នៃរបាយការណ៍នេះ។

១២. ធនធាននិងឧបករណ៍សម្រាប់ការសិក្សា

ដើម្បីផ្តល់នូវឧត្តមភាពក្នុងការអប់រំឆ្មប ការអប់រំត្រូវការឱ្យមានសម្ភារៈរូបវន្តដែលអាចចូលដំណើរការបាន ទាន់សម័យ និងពាក់ព័ន្ធ។ ចំណុចស្នូលនេះត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងផ្នែក ១.៣.៣.៤ នៃរបាយការណ៍នេះ។

១៣. អំពីសិទ្ធិមនុស្ស

ដើម្បីធ្វើឱ្យឧត្តមភាពក្នុងការអប់រំឆ្មប ត្រូវធ្វើការតាម ហើយបង្រៀននិស្សិតឱ្យធ្វើតាមវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។ ចំណុចស្នូលនេះ ត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងជំពូកទី ៣ នៃរបាយការណ៍នេះ។

១៤. ស្រាវជ្រាវនៅក្នុងឆ្មប

ដើម្បីផ្តល់នូវឧត្តមភាពក្នុងការស្រាវជ្រាវលើជំនាញឆ្មប ត្រូវផ្តោតសំខាន់លើការសំរេចបាននូវការយល់ដឹងអំពីការស្រាវជ្រាវនិងបង្រៀននិស្សិតឱ្យអនុវត្តតាមវិធីសាស្ត្រអនុវត្តជាក់ស្តែង។ ចំណុចស្នូលនេះត្រូវបានពន្យល់លម្អិតបន្ថែមទៀតនៅក្នុងជំពូកទី ៤ នៃរបាយការណ៍នេះ។

ជំពូកទី២ សមត្ថភាពស្នូលសម្រាប់ជំនាញឆ្មបក្នុងគ្លីនិក

២.០ សេចក្តីផ្តើមនៃជំពូក

ជំពូកបន្ទាប់បង្ហាញពីការអនុវត្តដ៏ល្អបំផុតក្នុងការអនុវត្តជំនាញឆ្មបមូលដ្ឋាន។ គោលបំណងនៃគម្រោង SafeMa ដើម្បីបង្កើតវគ្គសិក្សាជំនាញឆ្មបកម្រិតខ្ពស់ដែលមានម៉ូឌុលចំនួន ៨ ដែលអាចត្រូវបានបង្រៀនដូចជាវគ្គខ្លីនិងសម្របសម្រួលកម្មសិក្សា (៥p:២៣)។ គោលបំណងនៃការវិភាគ គម្លាត WP1 ភារកិច្ចទី ២

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ដើម្បីកំណត់និងផ្គូផ្គងកង្វះនៃជំនាញគ្លីនិកជាក់លាក់ស្របតាមអាទិភាពជាតិនៅក្នុងប្រទេសជាដៃគូមានប្រទេសវៀតណាមនិងកម្ពុជា។ ខាងក្រោមនេះគឺជាគ្រោងស្តង់ដារល្អបំផុតសម្រាប់ ICM សម្រាប់សមត្ថភាពចាំបាច់ដើម្បីការអនុវត្តជំនាញឆ្មបមូលដ្ឋាន (៤) ដែលនឹងបង្កើតជាមូលដ្ឋានសម្រាប់ការវិភាគគម្លាតនៃគម្រោង SafeMa, WP1 កិច្ចការ ២ និងកំណត់បន្ថែមទៀតនៃជំនាញគ្លីនិកឆ្មបមូលដ្ឋាននិងកម្រិតខ្ពស់ដែលផ្តោតទៅលើវគ្គសិក្សាក្រោយឧត្តមរបស់ គម្រោង SafeMa។

ដូចមានចែងក្នុង ១.៣.២.២ ឆ្មបដែលបញ្ចប់ការសិក្សាគួរតែបានទទួលបានសមត្ថភាពអប្បបរមាសម្រាប់ការអនុវត្តឆ្មបមូលដ្ឋាននិងជាអ្នកអនុវត្តស្វយ័ត។

និយមន័យ ICM របស់ឆ្មបមានដូចខាងក្រោម៖

ឆ្មបគឺជាមនុស្សម្នាក់ដែលបានបញ្ចប់ដោយជោគជ័យនូវកម្មវិធីអប់រំឆ្មបដែលត្រូវបានទទួលស្គាល់យ៉ាងត្រឹមត្រូវនៅក្នុងប្រទេសរបស់ខ្លួន ហើយផ្អែកលើសមត្ថភាពចាំបាច់របស់ ICM សំរាប់ការអនុវត្តឆ្មបមូលដ្ឋាននិងក្របខណ្ឌនៃស្តង់ដារអន្តរជាតិនៃការអប់រំឆ្មបដែលបានទទួលនូវលក្ខណៈសម្បត្តិចាំបាច់ដែលត្រូវចុះបញ្ជីឬមានការអនុញ្ញាតស្របច្បាប់ដើម្បីអនុវត្តឆ្មប និងប្រើចំណងជើងថា“ ឆ្មប” និងអ្នកដែលបង្ហាញពីសមត្ថភាពក្នុងការអនុវត្តឆ្មប។ (13p:1)

សមត្ថភាពចាំបាច់របស់ ICM គឺឯកសារដែលបង្កើតសមត្ថភាពសម្រាប់ការអនុវត្តមូលដ្ឋាន។ ឯកសារនេះបានដាក់បញ្ជាក់ពីចំណេះដឹង ជំនាញ និងអាកប្បកិរិយាឆ្មបមូលដ្ឋានចាំបាច់ត្រូវមានដើម្បីអនុវត្តប្រកបដោយសុវត្ថិភាពក្នុងស្ថានភាពណាមួយ។ ដូច្នេះឯកសារនេះអាចផ្តល់នូវសមត្ថភាពជាសកលដែលបានបង្កើតឡើងសម្រាប់ការអនុវត្តឆ្មប។

២.១ សមាសភាគក្នុងការអនុវត្តឆ្មប

ខាងក្រោមនេះ ICM គឺជាសមត្ថភាពចាំបាច់ចំនួន៧ សម្រាប់ការអនុវត្តឆ្មបមូលដ្ឋាន ត្រូវបានគូសបញ្ជាក់ (៤) ។ សមត្ថភាពនីមួយៗ ត្រូវបានអនុវត្តជាឧទាហរណ៍ពីរបៀបនៃស្តង់ដារល្អបំផុតដែលអាចត្រូវបានបំពេញ។

២.១.១ សមត្ថភាពទី១៖ សមត្ថភាពសង្គម អេពីដេមីសាស្ត្រ និងការមើលថែមាតានិងទារក

ឆ្មបមានចំណេះដឹងនិងជំនាញសម្ភព សសៃប្រសាទ វិទ្យាសាស្ត្រសង្គម សុខភាពសាធារណៈ និងក្រមសីលធម៌ដែលជាមូលដ្ឋាននៃគុណភាពខ្ពស់ វប្បធម៌ទូទៅពាក់ព័ន្ធការថែទាំសមរម្យសម្រាប់ស្ត្រីទារកទើបនឹងកើត។

ឧទាហរណ៍ពីវិធីដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្តឆ្មប៖

ឆ្មបគួរតែមានចំណេះដឹងអំពីសហគមន៍ និងសុខភាពរបស់សហគមន៍ដូចជា ប្រាក់ចំណូល អក្ខរកម្មការផ្គត់ផ្គង់ទឹកជាដើម។ ឆ្មបគួរតែមានជំនាញក្នុងការកត់ត្រា និងបកស្រាយសម្រាប់សេវាកម្មពាក់ពន្ធដែលបានផ្តល់ជូននៅគ្រប់ផ្នែកទាំងអស់នៃជំនាញ រួមមានអ្វីដែលបានធ្វើនិងអ្វីដែលត្រូវការ។

២.១.២ សមត្ថភាពទី ២៖ សមត្ថភាពការថែទាំមុនពេលមានផ្ទៃពោះ និងផែនការគ្រួសារ

ផ្តល់ការអប់រំ និងសេវាកម្មសុខភាពដែលមានគុណភាពខ្ពស់ និងការផ្តល់សេវាក្នុងសហគមន៍ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ និងផែនការគ្រួសារ។

ឧទាហរណ៍ ដើម្បីទទួលបានស្តង់ដារល្អបំផុត សម្រាប់សមត្ថភាពក្នុងការអនុវត្ត៖

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ឆ្មបគួរតែមានចំណេះដឹងអំពីវិធីសាស្ត្រនិងជំនាញផែនការគ្រួសារនាពេលបច្ចុប្បន្នក្នុងការចូលរួមជាមួយស្ត្រីនិងក្រុមគ្រួសារក្នុងការប្រឹក្សាយោបល់ជាមុនដោយផ្អែកលើស្ថានភាពបុគ្គលនិងចំណាប់អារម្មណ៍។

២.១.៣ សមត្ថភាពទី៣៖ សមត្ថភាពក្នុងការផ្តល់ការថែទាំអំឡុងពេលមានផ្ទៃពោះ

ឆ្មបត្រូវផ្តល់ការថែទាំមុនពេលសម្រាលដែលមានគុណភាពខ្ពស់ដើម្បីបង្កើនសុខភាពអំឡុងពេលមានផ្ទៃពោះរួមទាំងការព្យាបាលឱ្យបានទាន់ពេលវេលា។

ឧទាហរណ៍ វិធីដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្ត៖

ឆ្មបគួរតែមានចំណេះដឹងដើម្បីកំណត់សុខុមាលភាពរបស់ទារកក្នុងកំឡុងពេលមានផ្ទៃពោះ រួមទាំងចង្វាក់បេះដូងរបស់ទារកនិងលំនាំសកម្មភាព។ ឆ្មបគួរមានជំនាញក្នុងការកំណត់គម្លាតពីភាពធម្មតាក្នុងពេលមានផ្ទៃពោះនិងចាប់ផ្តើមដំណើរការបញ្ជូនសម្រាប់លក្ខខណ្ឌដែលត្រូវការអន្តរាគមន៍ខ្ពស់។

២.១.៤ សមត្ថភាពទី៤៖ សមត្ថភាពក្នុងការផ្តល់ការថែទាំកំឡុងពេលសម្រាលកូន

ឆ្មបផ្តល់ការថែទាំប្រកបដោយគុណភាពខ្ពស់និងយកចិត្តទុកដាក់ខ្ពស់ក្នុងកំឡុងពេលធ្វើការសម្រាលកូន សម្អាតនិងដោះស្រាយស្ថានភាពបន្ទាន់ដើម្បីរក្សាសុខភាពរបស់ស្ត្រីនិងទារកទើបនឹងកើត។

ឧទាហរណ៍ ដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្ត៖

ឆ្មបគួរតែមានចំណេះដឹងអំពីការវិវឌ្ឍន៍ធម្មតាខ្យល់ដកដង្ហើយរបស់ទារកនិងជំនាញក្នុងការតាមដានវឌ្ឍនភាពនៃខ្យល់ដកដង្ហើយរបស់ទារកដោយប្រើឧបករណ៍ថតសំឡេងឬឧបករណ៍ស្រដៀងគ្នាសម្រាប់ថត។

២.១.៥ សមត្ថភាពទី ៥៖ សមត្ថភាពការថែទាំដល់ស្ត្រីក្រោយពេលសម្រាល

ឆ្មបផ្តល់ការថែទាំសុខភាពក្រោយសម្រាលកូនដែលមានលក្ខណៈទូលំទូលាយនិងមានគុណភាពខ្ពស់សម្រាប់ស្ត្រី។

ឧទាហរណ៍ ដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្ត៖

ឆ្មបគួរតែមានចំណេះដឹងអំពីសញ្ញានិងរោគសញ្ញានៃស្ថានភាពគ្រោះថ្នាក់ដល់ជីវិតដែលអាចកើតមានជាលើកដំបូងអំឡុងពេលឆ្លងទន្លេ។ ឧទាហរណ៍ ការហូរឈាមតាមទ្វារមាសជាប់លាប់ ការស្ទះសរសៃឈាមខួរក្បាលក្រោយឆ្លងទន្លេនិងជំងឺក្រឡាភ្លើង ជំងឺសរសៃប្រសាទ និងជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ។ ឆ្មបគួរតែមានជំនាញក្នុងការផ្តល់ការព្យាបាលជាបន្ទាន់នៃការធ្លាក់ឈាមក្រោយពេលសម្រាលកូនហើយបញ្ជូនទៅផ្នែកពាក់ព័ន្ធប្រសិនបើចាំបាច់។

២.១.៦ សមត្ថភាពទី ៦៖ សមត្ថភាពការថែទាំទារកក្រោយសម្រាល

ឆ្មបផ្តល់ការថែទាំប្រកបដោយគុណភាពខ្ពស់ សម្រាប់ទារកតាំងពីកំណើតដល់អាយុ ២ ខែ។

ឧទាហរណ៍ ដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្ត៖

ឆ្មបគួរតែមានចំណេះដឹងអំពីធាតុផ្សំនៃការវាយតម្លៃអំពីស្ថានភាពបន្ទាន់និងបន្តបន្ទាប់របស់ទារកទើបនឹងកើត (រួមទាំងប្រព័ន្ធដាក់ពិន្ទុ APGAR ឬវិធីសាស្ត្រវាយតម្លៃអត្រាដកដង្ហើមនិងចង្វាក់បេះដូង)។ ឆ្មបគួរតែមានជំនាញក្នុងការផ្តល់ការថែទាំភ្លាមៗដល់ទារកទើបនឹងកើតរួមទាំងការសម្ងួត និងធ្វើអោយអ៊ុនៗដល់ទារក ដើម្បីធានាដល់ការដកដង្ហើមនិងការកាត់ទងផ្ចិតជាដើម។

២.១.៧ សមត្ថភាពទី៧៖ សមត្ថភាពការថែទាំទាក់ទងនឹងការរំលូតកូន

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ឆ្មបផ្តល់ជូននូវសេវាកម្មថែទាំទាក់ទងនឹងការរំលូតកូនតាមលក្ខណៈវប្បធម៌ជាលក្ខណៈបុគ្គល

សម្រាប់ស្ត្រីដែលត្រូវការឬជួបប្រទះនឹងការបញ្ចប់ឬបាត់បង់ការមានផ្ទៃពោះដែលត្រូវនឹងច្បាប់និងបទ ប្បញ្ញត្តិដែលអាចអនុវត្តបាននិងស្របតាមពិធីសារថ្នាក់ជាតិ។

ឧទាហរណ៍ ដើម្បីទទួលបានស្តង់ដារល្អបំផុតសម្រាប់សមត្ថភាពក្នុងការអនុវត្តៈ

ឆ្មបគួរមានចំណេះដឹងមូលដ្ឋានអំពីរោគសញ្ញាផលវិបាកនៃការរំលូតកូននិងស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិត ឧទាហរណ៍ ការហូរឈាមតាមទ្វារមាសជាប់លាប់។ ឆ្មបគួរតែមានជំនាញក្នុងការកំណត់សូចនាករនៃផលវិបាកទាក់ទងនឹងការរំលូតកូន (រួមទាំងការបំផ្លាញស្បូន)។

ជំពូកទី៣៖ អំពីសិទ្ធិមនុស្ស

៣.០ ការណែនាំអំពីជំពូក

SafeMa ប្តេជ្ញាអនុវត្តតាមវិធីសាស្ត្រពីសិទ្ធិមនុស្ស (HRBA) ក្នុងការអភិវឌ្ឍកម្មវិធី SafeMa ។ គោលបំណងរបស់ HRBA គឺដើម្បីគាំទ្រកាន់តែប្រសើរនូវលទ្ធផលនៃការអភិវឌ្ឍប្រកបដោយចិរភាពបន្ថែមទៀតនៃវគ្គសិក្សា SafeMa ដោយដោះស្រាយភាពមិនស្មើភាពគ្នា ការរើសអើង និងទំនាក់ទំនងអំណាចអយុត្តិធម៌ដែលភាគច្រើនជាបេះដូងនៃបញ្ហាដល់ការអភិវឌ្ឍន៍។ ជំពូកបន្ទាប់នឹងសង្កត់ធ្ងន់អំពីការយោគយល់គ្នារបស់អង្គការសុខភាពពិភពលោកជាមួយអង្គការសហប្រជាជាតិ (UN) ស្តីពី HRBA ចាប់ពីឆ្នាំ ២០០៣ និងបញ្ហាប្រឈមដែលអាចមានក្នុងបរិបទ Safema ដោយយោងទៅលើគំនិតនៃអំពើហិង្សាសម្ភព។ សេចក្តីប្រកាសរួមរបស់អង្គការសហប្រជាជាតិ (UN) ចំពោះ HRBA បានក្លាយជាចំណុចយោង និងគោលការណ៍ណែនាំសម្រាប់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន ដូច្នេះវាសមរម្យសម្រាប់ការគូសបញ្ជាក់អំពី SafeMa HBRA.

៣.១ ទស្សនទានស្តីពីសិទ្ធិមនុស្សក្នុងបរិបទ SafeMa

សេចក្តីប្រកាសរួមរបស់អង្គការសហប្រជាជាតិ (UN) ស្តីពី HRBA ក្នុងបរិបទសុខភាពបានសង្កត់ធ្ងន់ពីគោលដៅចុងក្រោយនៃគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីសុខភាពទាំងអស់គឺដើម្បីជំរុញបន្ថែមទៀតការធ្វើឱ្យសម្រេចបាននូវសិទ្ធិទទួលបានសុខភាពនិងសិទ្ធិទាក់ទងនឹងសុខភាពដទៃទៀត ដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ បទដ្ឋានសិទ្ធិមនុស្សគួរតែផ្តល់ការណែនាំក្នុងការកំណត់ធាតុច្បាស់លាស់នៃគោលដៅសុខភាព (១៤) ដូច្នេះវគ្គសិក្សា SafeMa ចាំបាច់ត្រូវមានការណែនាំពីស្តង់ដារ HRBA នៅពេលកំណត់គោលបំណងនៃវគ្គសិក្សាហើយគួរតែអភិវឌ្ឍសមត្ថភាពដើម្បីបំពេញកាតព្វកិច្ចទាំងនេះ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងព្រោះនេះជាស្នូលនៃ HRBA (១៤)។ អង្គការសហប្រជាជាតិ (UN) បានកំណត់អត្តសញ្ញាណធាតុសំខាន់បីនៅក្នុង HRBA៖ គោលដៅដំណើរការ និងលទ្ធផល។ ធាតុខាងក្រោមនេះ នឹងត្រូវបង្ហាញពីទិដ្ឋភាពសំខាន់ៗទាក់ទងនឹង បរិបទរបស់ SafeMa នឹងត្រូវបានកំណត់។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Source (14 p:3)

៣.១.១ គោលដៅវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស

វាជាធាតុស្នូលក្នុង HRBA នៃការអភិវឌ្ឍន៍កម្មវិធី កិច្ចសហប្រតិបត្តិការ គោលនយោបាយ និងជំនួយបច្ចេកទេស គួរតែធ្វើឱ្យសម្រេចបាននូវការគោរពសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងឧបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត (១៤)។ ដើម្បី អនុវត្តតាមគោលដៅវគ្គសិក្សា SafeMa នេះ ចាំបាច់ត្រូវធ្វើសមាហរណកម្មជាប្រព័ន្ធនិងផ្តោតការយកចិត្តទុកដាក់ពង្រឹងសិទ្ធិមនុស្សជាពិសេសសិទ្ធិសុខភាពក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។

យោងតាមអង្គការសុខភាពពិភពលោក ចំណុចសំខាន់ៗក្នុងសិទ្ធិទទួលបានសុខភាពបានពង្រីកទាំងការថែរក្សាសុខភាពឱ្យបានទាន់ពេលវេលានិងសមស្របនិងកត្តាកំណត់សុខភាព (១៤)។ ដូច្នេះនិស្សិតដែលបញ្ចប់ការសិក្សាវគ្គសិក្សា SafeMa ចាំបាច់ត្រូវទទួលបានចំណេះដឹងអំពីសារៈសំខាន់នៃការគោរពសិទ្ធិមនុស្ស និងត្រូវបានបង្រៀនអំពីការតស៊ូមតិសម្រាប់ស្ត្រី ដូច្នេះជម្រើសនៃការថែទាំសុខភាពរបស់ពួកគេត្រូវបានគោរព។ ទាំងនេះក៏ជាទស្សនទានរបស់ ICM ផងដែរ (១) ។ និស្សិតដែលបញ្ចប់ការសិក្សាចាំបាច់ត្រូវមានចំណេះដឹង អំពីកត្តាកំណត់សុខភាព។

៣.១.២ ដំណើរការត្រូវផ្អែកលើការគោរពសិទ្ធិមនុស្ស

ធាតុស្នូលនៅក្នុង HRBA ដែលមានសារៈសំខាន់ វាមិនត្រឹមតែផ្តល់លទ្ធផលប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាដំណើរការផងដែរ (១៤) ។ ស្តង់ដារនិងគោលការណ៍សិទ្ធិមនុស្ស ដូចជាការចូលរួម សមភាព ការមិនរើសអើង និងគណនេយ្យភាពគួរតែត្រូវបានបញ្ចូលទៅក្នុងគ្រប់ដំណាក់កាលនៃការធ្វើផែនការនិងការប្រតិបត្តិនៃវគ្គសិក្សា SafeMa។

ដូច្នេះនិស្សិតដែលបានបញ្ចប់ការសិក្សាវគ្គ SafeMa ចាំបាច់ត្រូវមានចំណេះដឹងអំពីវិធីគាំទ្រដល់ការចូលរួមរបស់អតិថិជនដើម្បីធានាថាអតិថិជនពិតជាមានសិទ្ធិទទួលបានការចូលរួមដោយសេរីមិនរើសអើង និងមានអត្ថន័យក្នុងការសម្រេចចិត្តលើបញ្ហាសុខភាពដែលជះឥទ្ធិពលដោយផ្ទាល់ដល់ពួកគេ។ ពិតជាមានសារៈសំខាន់ដែលនិស្សិតបញ្ចប់ការសិក្សាទទួលបានចំណេះដឹងនិងជំនាញក្នុងការប្រាស្រ័យទាក់ទង ដូច្នេះពួកគេអាចផ្តល់ព័ត៌មានពាក់ព័ន្ធដល់អតិថិជនតាមទំរង់ដែលអាចទទួលយកបាន។ ឧទាហរណ៍ អាយុ ភេទ ជនជាតិភាគតិច សាសនា និងវប្បធម៌ ព្រោះថាការចូលរួមអាចមានអត្ថន័យប្រសិនបើព័ត៌មានពាក់ព័ន្ធអាចរកបានហើយសេរីភាពក្នុងការបង្កើតសមាគមត្រូវបានធានា (១៤)។

៣.១.៣ លទ្ធផលដែលផ្អែកលើការគោរពសិទ្ធិមនុស្ស

ធាតុស្នូលនៅក្នុង HRBA បានផ្តោតលើការអភិវឌ្ឍសមត្ថភាពសម្រាប់អ្នកទទួលកាតព្វកិច្ច។ ក្នុងបរិ បទនេះ និស្សិតដែលបានបញ្ចប់វគ្គសិក្សាSafeMaដើម្បីបំពេញតាមកាតព្វកិច្ចរបស់ពួកគេ(១៤)។ អង្គការសុខភាពពិភពលោកបានសង្កត់ធ្ងន់ថា មានកាតព្វកិច្ចបីប្រភេទ គឺការគោរព ការការពារ និងការបំពេញ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

និស្សិតដែលបានបញ្ចប់ការសិក្សាវគ្គ SafeMa ចាំបាច់ត្រូវមានចំណេះដឹងអំពីគំនិតនៃការគោរព និងមានកាតព្វកិច្ចធានាការអនុវត្តដោយគោរព និងគាំទ្រការអនុវត្តដែលមិនជ្រៀតជ្រែកដោយផ្ទាល់ឬដោយប្រយោលជាមួយនឹងសិទ្ធិទទួលបានសុខភាព។
និស្សិតបញ្ចប់ការសិក្សាវគ្គ SafeMa ចាំបាច់ត្រូវមានចំណេះដឹងអំពីគំនិតនៃការបំពេញនិងកាតព្វកិច្ចដើម្បីអនុវត្តវិធានការណ៍សមស្របដើម្បីគាំទ្រដល់ការសំរេចបានពេញលេញរបស់អតិថិជនចំពោះសិទ្ធិទទួលបានសុខភាព។
កាតព្វកិច្ចទាំងនេះ មានសារៈសំខាន់ជាពិសេសទាក់ទងនឹងកាតព្វកិច្ចការពារអតិថិជនពីហានិភ័យនៃអំពើហិង្សាក្នុងសម្រាល។

ជំពូកទី ៤ ការស្រាវជ្រាវក្នុងជំនាញឆ្មប

៤.០ សេចក្តីផ្តើមជំពូក

ជំពូកនេះនឹងបង្ហាញពីការអនុវត្តការស្រាវជ្រាវដ៏ល្អបំផុតនៅក្នុងជំនាញឆ្មបក្នុងបរិបទ SafeMa ។ ជំពូកនេះនឹងសង្កត់ធ្ងន់អំពីវិធីស្រាវជ្រាវដែលអាចត្រូវបានប្រើប្រាស់ក្នុងការអប់រំនិងការអនុវត្តឆ្មបតាមរយៈទស្សនទាននៃការអនុវត្តជាក់ស្តែង។

ជំពូកនេះបង្កើតបានជាមូលដ្ឋានសម្រាប់ការវិភាគគម្លាតនៃ SafeMa សម្រាប់ WP1 task 2 និងផ្តល់នូវនិយមន័យបន្ថែមលើប្រធានការស្រាវជ្រាវឆ្មប ដែលត្រូវការផ្តោតលើវគ្គសិក្សាក្រោយឧត្តមសិក្សារបស់ SafeMa ។

៤.១ ការសិក្សាស្រាវជ្រាវក្នុងជំនាញឆ្មប

ការស្រាវជ្រាវអាចកំណត់បានតាមវិធីជាច្រើន។ ក្នុងរបាយការណ៍របស់ SafeMa ការស្រាវជ្រាវនឹងត្រូវបានកំណត់ជា “ការស៊ើបអង្កេតយ៉ាងម៉ត់ចត់និងមានលក្ខណៈជាប្រព័ន្ធដែលធ្វើឡើងតាមខ្នាតនិងប្រើប្រាស់វិធីសាស្ត្រសមស្របជាមួយនឹងបញ្ហាដែលបានស៊ើបអង្កេតនិងបង្កើតឡើងដើម្បីនាំទៅដល់ការចូលរួមចំណែកដល់ចំណេះដឹងទូទៅ” (១៦ ទំ .៦) ។

ការស្រាវជ្រាវមានឥទ្ធិពលផ្នែកវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រយ៉ាងខ្លាំង ទាំងនេះអាចជាហេតុផលសម្រាប់ការស្ទាក់ស្ទើររបស់ឆ្មបក្នុងការស្រាវជ្រាវ និងហេតុផលដែលមិនបានរំពឹងទុកក្នុងការស្រាវជ្រាវឆ្មបដោយអ្នកជំនាញសុខភាពផ្សេងទៀត និងឆ្មបខ្លួនឯង (១៦ ទំ: ៤) ។ ដូច្នេះវាជាការភ្ញាក់រលឹកនៃការលើកកម្ពស់ការស្រាវជ្រាវក្នុងជំនាញឆ្មបក៏រួមបញ្ចូលវិធីសាស្ត្របំប្លែងយេនឌ័រដើម្បីទទួលជោគជ័យ។

សមត្ថភាពក្នុងការយល់និងរិះរករបាយការណ៍ស្រាវជ្រាវគួរតែត្រូវបានគាំទ្រនិងលើកកម្ពស់ក្នុងការអប់រំឆ្មបដើម្បីផ្តល់ទំនុកចិត្តដល់ឆ្មបក្នុងការអានឯកសារដោយប្រើក្របខ័ណ្ឌវាយតម្លៃដែលជួយពួកគេក្នុងការកំណត់តម្លៃរបស់ពួកគេជាជាងជៀសវាងឬបរិហារការស្រាវជ្រាវទាំងអស់តាមរយៈការភ័យខ្លាច ឬភាពល្ងង់ខ្លៅ (១៦ ទំ: ៤) ។

ការលើកឡើងថាការយល់ដឹងអំពីការស្រាវជ្រាវគឺជាជំហានដំបូងដើម្បីអនុវត្តជាក់ស្តែង (១៦) ដែលត្រូវបានពិពណ៌នាក្នុង ៤.២ ដើម្បីឱ្យការស្រាវជ្រាវមានន័យអាចធ្វើដូចតទៅនេះ (១៦p: ៨)៖

- កំណត់ប្រធានបទដែលអាចទទួលបានអត្ថប្រយោជន៍ពីការស្រាវជ្រាវក្នុងការអនុវត្តផ្ទាល់ខ្លួនរបស់អ្នក

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- កំណត់ប្រធានបទក្នុងការផ្តល់សេវាដែលអាចទទួលបានអត្ថប្រយោជន៍ពីការស្រាវជ្រាវ
- កំណត់អត្តសញ្ញាណគំនិត ឬបច្ចេកវិទ្យាថ្មីៗដែលត្រូវការស៊ើបអង្កេត
- អានឯកសារបោះពុម្ពផ្សាយទាក់ទងនឹងការអនុវត្ត និងវាយតម្លៃភាពសមស្របសម្រាប់ការអនុវត្ត
- ស្វែងរកអក្សរសិល្ប៍ណាមួយដើម្បីបំពេញតំរូវការរបស់អតិថិជន
- ធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវងាយស្រួលសម្រាប់អ្នកប្រើប្រាស់ជាផ្នែកមួយនៃសកម្មភាពអប់រំរបស់ឪពុកម្តាយ
- ជួយអ្នកដទៃឱ្យយល់ពីភាពខ្លាំងនិងភាពខ្សោយនៃលទ្ធផលស្រាវជ្រាវ
- ផ្តល់យោបល់និងគាំទ្រដល់ស្ត្រីដែលត្រូវបានស្នើសុំឱ្យចូលរួមក្នុងការស្រាវជ្រាវ
- គាំទ្រដល់ឆ្មបដែលធ្វើការស្រាវជ្រាវ
- វាយតម្លៃលើការស្រាវជ្រាវដែលអ្នកកំពុងត្រូវបានស្នើសុំឱ្យប្រមូលទិន្នន័យនិងកំពុងត្រូវបានធ្វើឡើងត្រឹមត្រូវនិងជាចំណាប់អារម្មណ៍ល្អបំផុតរបស់អ្នកចូលរួម។

បញ្ជីនេះមិនរាប់បញ្ចូលគ្រប់ផ្នែកនៃការយល់ដឹងអំពីការស្រាវជ្រាវទេ ប៉ុន្តែអាចត្រូវបានប្រើជាមគ្គុទេសក៍ដើម្បីវាយតម្លៃប្រសិនបើឆ្មបមានការស្រាវជ្រាវក្នុងប្រទេសជាដៃគូមានប្រទេសកម្ពុជា និងវៀតណាម។

ការយល់ដឹងអំពីការស្រាវជ្រាវគួរតែត្រូវបានចាត់ទុកជាដំណើរការដែលកំពុងបន្តនូវការទទួលនិងប្រើប្រាស់ចំណេះដឹងដើម្បីពង្រឹងការយល់ដឹងស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅ (១៦ ទំព័រ ៥: ៥)។ ដើម្បីផ្តល់នូវឧត្តមភាពក្នុងការស្រាវជ្រាវក្នុងជំនាញឆ្មប ការអប់រំឆ្មបត្រូវការផ្តោតលើការចាប់ផ្តើមដំណើរការនៃការយល់ដឹងអំពីការស្រាវជ្រាវខណៈពេលដែលនិស្សិតត្រូវបានចុះឈ្មោះក្នុងការអប់រំឆ្មបនិងលើកកម្ពស់ការអនុវត្តជាក់ស្តែងដើម្បីគាំទ្រដល់ឆ្មបដោយប្រើវិធីសាស្ត្រអនុវត្តជាក់ស្តែងបន្ទាប់ពីបញ្ចប់ការសិក្សានឹងត្រូវបានពិពណ៌នាដូចខាងក្រោម។

៤.២ ការអនុវត្តជាក់ស្តែង

ការអនុវត្តជាក់ស្តែងត្រូវបានពិពណ៌នាយ៉ាងក្បោះក្បាយដោយលោក David Sackett Et Al ដែលបានកំណត់ថា“ ការប្រើប្រាស់មនសិការ និងការកាត់សេចក្តីដោយប្រើប្រាស់ភាពជាក់ស្តែងពេលបច្ចុប្បន្នក្នុងការសម្រេចចិត្តអំពីការថែទាំអ្នកជំងឺម្នាក់ៗ” (១៦ ទំ: ៧)។ វិធីសាស្ត្រអនុវត្តន៍ជាក់ស្តែងត្រូវបានពិចារណាជាយូរមកហើយអំពីស្តង់ដារសម្រាប់ឧត្តមភាពក្នុងការថែរក្សាគុណភាពនៅក្នុង វិស័យសុខាភិបាល ដូច្នេះគួរតែជាវិធីសាស្ត្រការអនុវត្តន៍ ដែល SafeMa បានពិពណ៌នានៅក្នុង ១.៣.១.៣ និង ១.៤.១ នៃរបាយការណ៍នេះ។

ការអនុវត្តជាក់ស្តែងតម្រូវឱ្យមានការរួមបញ្ចូលចំណេះដឹងនៃការស្រាវជ្រាវល្អបំផុតជាមួយនឹងជំនាញគ្លីនិករបស់អ្នកអនុវត្តនិងផ្តល់តម្លៃដល់អ្នកជំងឺ (១៧) ។

ភស្តុតាងការស្រាវជ្រាវល្អបំផុត មានន័យថា ការស្រាវជ្រាវដែលមានសុពលភាពទៅនឹងបច្ចុប្បន្ន និងពាក់ពន្ធគ្លីនិក។

ជំនាញគ្លីនិកត្រូវបានកំណត់ជាជំនាញវិជ្ជាជីវៈសុខភាពក្នុងការប្រើប្រាស់ជំនាញគ្លីនិកនិងបទពិសោធន៍ការងារកន្លងមកដើម្បីរកឱ្យឃើញយ៉ាងរហ័សនូវការធ្វើរោគវិនិច្ឆ័យនៃស្ថានភាពសុខភាព របស់អ្នកជំងឺ។

គុណតម្លៃរបស់អ្នកជំងឺត្រូវបានការរំពឹងទុកថា អ្នកជំងឺម្នាក់ៗនាំមកនូវការព្យាបាលនិងស្ថានភាពរបស់គាត់ដូចជាស្ថានភាពគ្លីនិកផ្ទាល់ខ្លួន។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ដូច្នេះជំនាញឆ្មបត្រូវការរួមបញ្ចូលគ្នានូវជំនាញនិងឥរិយាបថដ៏សំខាន់ដើម្បីអាចអនុវត្តជាក

តស្តែងបានរួមមាន (១៦ ទំ: ៨)៖

- សង្កេតការណ៍និងកំណត់តម្រូវការរបស់ស្ត្រីម្នាក់ៗ
- ផ្តោតលើតំរូវការស្ត្រី
- ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើឱ្យស្ត្រីក្លាយជាដៃគូស្មើគ្នាក្នុងការមើលថែទាំពួកគេ
- មានភាពបត់បែនក្នុងការអនុវត្ត ដូច្នេះអាចអភិវឌ្ឍជំនាញគ្លីនិកដោយផ្អែកលើការអនុវត្តផ្ទាល់ខ្លួននិងបទពិសោធន៍
- ការសាកសួរនិងបើកចំហចំពោះសំណួរនៃការអនុវត្ត
- អ្នកសិក្សាពេញមួយជីវិត ចំណេះដឹងមិនដែលមានទីបញ្ចប់ទេហើយត្រូវតែបន្តធ្វើឱ្យខ្លួនគេទាន់សម័យនិងមានមនសិការ
- ការស្រាវជ្រាវស្វែងយល់

ប្រសិនបើការរួមបញ្ចូលគ្នានៃលក្ខណៈនេះ ត្រូវបានផ្សព្វផ្សាយនៅក្នុងការអប់រំឆ្មបនិងវិជ្ជាជីវៈរបស់ បណ្តាប្រទេសជាដៃគូមានប្រទេសកម្ពុជា និងវៀតណាមវានឹងអនុញ្ញាតឱ្យឆ្មបប្រើប្រាស់ការស្រាវជ្រាវប្រកបដោយប្រសិទ្ធភាពនិងប្រកបដោយយុត្តិធម៌ទៅនឹងតម្រូវការរបស់អ្នកជំងឺម្នាក់ៗ (១៦)

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Bibliography

(1) ICM 2013, Global Standards for Midwifery Education. Amended 2013.

(2) ICM 2013, Global Standards for Midwifery Education 2010, Companion Guidelines. Amended 2013.

(3) WHO 2009, Global standards for the initial education of professional nurses and midwives. Geneva.

(4) ICM 2013, Essential competencies for basic midwifery practice. 2010 Revised 2013.

(5) SafeMa 2018, Education Hubs for Excellence in midwifery detailed description of the project.

Erasmus+

(6) WHO website. Available at:

https://www.who.int/

Accessed 29-03-2019

(7) Viet Nam Ministry of Health, 2017, Final Report – Viet Nam Midwifery Report 2016. Hanoi 2017

(8) HERA, UNFPA 2017, Universal Health Coverage for Sexual and Reproductive Health in the Asia-Pacific Region

(9) ICM 2014, International Code of Ethics for Midwives, Reviewed and adopted at Prague Council meeting 2014.

(10) Cambodia Ministry of Health, 2016, Fast Track Initiative Road Map for Reducing Maternal and Newborn Mortality 2016-2020.

(11) WHO 2017, Strengthening quality midwifery education: Meeting report. WHO meeting report July 25-26 2016. Available at:

https://apps.who.int/iris/bitstream/handle/10665/259278/WHO-FWC-MCA-17.12-eng.pdf?sequence=1

Accessed 29-03-2019

(12) UN Sustainable Development Goal 3. Available at: https://www.un.org/sustainabledevelopment/health/

Accessed 29-03-2019

(13) ICM 2014, Philosophy and Model of Midwifery Care. Reviews and adopted at Prague Council meeting, 2014

(14) WHO – A Human Rights-Based approach to Health. Available at: https://www.who.int/hhr/news/hrba_to_health2.pdf

Accessed 29-03-2019

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

(15) WHO Statement– The prevention and elimination of disrespect and abuse during facilitybased childbirth. Available at:

https://apps.who.int/iris/bitstream/handle/10665/134588/WHO_RHR_14.23_eng.pdf;jsessionid=ADA092B86DC07C59FBA8DE571B24A0A9?sequence=1

Accessed 29-03-2019

(16) Cluett E.R, Bluff R 2006, Principles and Practice of Research in Midwifery, Second edition, Elsevier Limited.

(17) Straus S.E. et al 2011, Evidence-Based Medicine – How to Practice and Teach EBM, Third edition, Elsevier Limited.

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.